មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# **កំណត់ត្រាសង្ខេប**

# **កម្ពុជា ៖ លទ្ធិប្រជាធិបតេយ្យកំពុងរងការគំរាមកំហែង**

ខែកញ្ញា ឆ្នាំ២០១៥

## **ខ្លឹមសារសង្ខេប**

នៅប៉ុន្មានខែចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជា (“រដ្ឋាភិបាល”) បានរឹតត្បិតទៅលើសេរីភាពមូលដ្ឋានយ៉ាងខ្លាំង និងបានព្យាយាមគាបសង្កត់សំឡេងជំទាស់ ដែលនេះជាការគំរាមកំហែងធ្ងន់ធ្ងរដល់លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅកម្ពុជា។ បើទោះជាមានការការពារផ្នែកច្បាប់ដែលមានចែងនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិក៏ដោយ ក៏ការរំលោភបំពានទៅលើសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានកំពុងកើនឡើងក្នុងកម្រិតមួយគួរឱ្យព្រួយបារម្ភនៅកម្ពុជា។ ម្យ៉ាងទៀត ការគាបសង្កត់នាពេលថ្មីៗនេះរបស់រដ្ឋាភិបាលទៅលើលទ្ធិប្រជាធិបតេយ្យ និងការតវ៉ាដោយសន្តិវិធីអាចនឹងកើតមានឡើងក្នុងអំឡុងពេលការបោះឆ្នោតឃុំ/សង្កាត់ឆ្នាំ២០១៧ និងការបោះឆ្នោតថ្នាក់ជាតិ ឆ្នាំ២០១៨ខាងមុខ។ ខណៈដែលការបោះឆ្នោតខាងមុខកាន់តែរំកិលជិតមកដល់ រដ្ឋាភិបាលបានបង្ហាញពីការប្ដេជ្ញាចិត្តធ្វើអ្វីគ្រប់បែបយ៉ាងតាមអំណាចរបស់ខ្លួន ដើម្បីបង្ក្រាបទៅលើសំឡេងជំទាស់។ ជាក់ស្ដែង ករណីនេះបាននាំឱ្យមានការរំលោភបំពានជាច្រើនទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ការប្រមូលផ្ដុំ និងការបង្កើតសមាគម ព្រមទាំងការបង្កើតនូវបរិយាកាសនយោបាយ មិនល្អ និងមានការគំរាមកំហែងពីថ្នាក់ដឹកនាំនយោបាយ និងថ្នាក់ដឹកនាំយោធាជាន់ខ្ពស់ផងដែរ។

បញ្ហានៃការរឹតត្បិតទៅលើសេរីភាពមូលដ្ឋានមិនត្រូវតាមច្បាប់នេះ កាន់តែមានសភាពធ្ងន់ធ្ងរឡើងនៅប៉ុន្មានឆ្នាំថ្មីៗនេះ។ គូបដិបក្ខនយោបាយ អង្គការសង្គមស៊ីវិល សហជីព និងប្រជាពលរដ្ឋទូទៅកំពុងប្រើប្រាស់បណ្ដាញព័ត៌មានសង្គមដើម្បីសម្ដែងមតិ និងរិះគន់ដែលត្រូវបានកំណត់មុខសញ្ញាជាប្រព័ន្ធ ខណៈដែលរដ្ឋាភិបាលប្រើប្រាស់អំណាចនយោបាយគ្រប់គ្រងទៅលើប្រព័ន្ធតុលាការ និងដាក់ចេញនូវច្បាប់ដែលមានលក្ខណៈគាបសង្កត់ រំលោភទៅលើសេរីភាពជាមូលដ្ឋាន។ ទន្ទឹមនេះ សេចក្ដីថ្លែងការណ៍របស់ថ្នាក់ដឹកនាំយោធាជាន់ខ្ពស់ដែលបង្ហាញពីភាពស្មោះស្ម័គ្ររបស់ខ្លួនចំពោះគណបក្សកាន់អំណាច ស្របពេលនឹងការព្រមានថានឹងមាន “*សង្គ្រាមស៊ីវិល*” ពីសំណាក់នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រសិនបើលោកបាត់បង់អំណាច ពិតជាបង្ហាញពីការគំរាមកំហែងផ្នែកហិង្សាផ្លូវកាយ ដើម្បីបង្កឲ្យមានបរិយាកាសតឹងតែងកើតមាននៅក្នុងប្រទេសកម្ពុជា នៅមុនពេលការបោះឆ្នោតជ្រើសរើសឃុំ/សង្កាត់ និងការបោះឆ្នោតថ្នាក់ជាតិ។ ការវិវឌ្ឍន៍ទាំងអស់នេះសុទ្ធតែមានទំនាក់

ទំនងគ្នា និងបង្ហាញឱ្យឃើញពីការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា ។ ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ គឺពិតជាចំណុចចាប់ផ្តើមនៃលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។ ការគោរពសិទ្ធិមនុស្ស ជាពិសេសសេរីភាពមូលដ្ឋាននានា ព្រមទាំងការបែងចែកអំណាចពិតប្រាកដគឺជាធាតុផ្សំដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ ។

នៅខែកញ្ញា ឆ្នាំ២០០៥ ប្រមុខរដ្ឋ និងរដ្ឋាភិបាលជាង១៧០ប្រទេស បានធ្វើការប្តេជ្ញានៅក្នុងជំនួបកំពូលពិភពលោកនៅទីក្រុងញូវយ៉ក ថា "*លទ្ធិប្រជាធិបតេយ្យ គឺជាតម្លៃសកលផ្អែកលើឆន្ទៈដែលបានសម្តែងឡើងដោយសេរីរបស់ប្រជាពលរដ្ឋដើម្បីប្តេជ្ញាទទួលយកប្រព័ន្ធនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ និងការចូលរួមដោយពេញលេញនៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរបស់ខ្លួន*"។[1] រដ្ឋទាំងនោះបានបន្តទទួលស្គាល់ថា "*លទ្ធិប្រជាធិបតេយ្យ ការអភិវឌ្ឍ និងការគោរពសិទ្ធិមនុស្សទាំងអស់ និងសេរីភាពមូលដ្ឋានគឺត្រូវផ្សាភ្ជាប់ទំនាក់ទំនងគ្នានឹងពឹងផ្អែកគ្នាទៅវិញទៅមក*"។[2] ដប់ឆ្នាំក្រោយមក ទំនាក់ទំនងនេះកាន់តែរឹងមាំ និងកាន់តែចាំបាច់ជាងមុនទៅទៀត។

កំណត់ត្រាសង្ខេបនេះមានគោលបំណងផ្តល់ការវិភាគពីការគំរាមគំហែងចំបងទៅលើលទ្ធិប្រជាធិបតេយ្យនៅកម្ពុជានាពេលបច្ចុប្បន្នក្នុងបរិបទសេរីភាពមូលដ្ឋាន។ ផ្នែកដំបូងនៃកំណត់ត្រានេះលើកឡើងសង្ខេបពីក្របខណ្ឌច្បាប់ជុំវិញសេរីភាពខាងការបញ្ចេញមតិ ការបង្កើតសមាគម និងការជួបប្រជុំនៅកម្ពុជា។ ផ្នែកទីពីរធ្វើការវិភាគពីការរឹតត្បិតទៅលើសេរីភាពមូលដ្ឋាននាពេលថ្មីៗនេះ និងលំហលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ផ្នែកបន្ទាប់ កំណត់ត្រាសង្ខេបនេះនឹងពិនិត្យនូវតួអង្គនានា ដែលត្រូវបានកំណត់មុខសញ្ញាពីសំណាក់រដ្ឋាភិបាលដែលជាផ្នែកមួយនៃការគាបសង្កត់ជាលក្ខណៈប្រព័ន្ធរបស់រដ្ឋាភិបាលទៅលើគូជំទាស់ ពោលគឺ គណបក្សប្រឆាំង សង្គមស៊ីវិល អ្នកប្រើប្រាស់អ៊ីនធឺណិត និងអ្នកសារព័ត៌មាន។ករណីសិក្សាជុំវិញការរឹតត្បិតសេរីភាពមូលដ្ឋាននាពេលថ្មីៗ ដែលចាត់ទុកជាការគំរាមកំហែងដល់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពសង្គមរបស់ប្រទេសជាតិត្រូវបានលើកយកបង្ហាញពីនិន្នាការបច្ចុប្បន្ន និងស្ថានភាពជាក់ស្តែង។ ផ្នែកចុងក្រោយលើកឡើងពីសេចក្តីសន្និដ្ឋានបញ្ចប់ ព្រមទាំងផ្តល់ជាអនុសាសន៍នានាដល់រាជរដ្ឋាភិបាលកម្ពុជា។ អនុសាសន៍ទាំងនោះរួមមាន ៖

- និរាករណ៍ច្បាប់ស្តីពីសមាគមនិងអង្គការដែលទើបតែត្រូវបានអនុម័តនាពេលថ្មីៗនេះ។
- បញ្ឈប់ការអនុម័តច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា រហូតមានការពិគ្រោះយោបល់ប្រកបដោយតម្លាភាពជាមួយសង្គមស៊ីវិលជាមុនសិន ព្រមទាំងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិសេរីភាពខាងការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណែត។ ។

[1] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ "លទ្ធផលនៃជំនួបកំពូលពិភពលោកឆ្នាំ២០០៥" ក/សេចក្តីសម្រេច/៦០/១ (ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៥) អាចស្វែងរកបានតាមរយៈតំណ ៖ http://daccess-dds-ny.un.org/doc/UNDOC/GEN/N05/487/60/PDF/N0548760.pdf?OpenElement។

[2] ប្រភពខាងលើ។

- ធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដើម្បីធានាដល់សេរីភាពខាងការបញ្ចេញមតិដល់អង្គការសង្គមស៊ីវិល ក្នុងអំឡុងពេលបោះឆ្នោត និងរារាំងការជ្រៀតជ្រែកនានាពីសំណាក់មន្ត្រីយោធា និងតុលាការក្នុងកិច្ចការបោះឆ្នោត។
- បញ្ឈប់ដំណើរការអនុម័តច្បាប់ស្តីពីសហជីព ប្រសិនបើច្បាប់នេះមិនមានការកែប្រែចំណុចសំខាន់ៗ និងមានកិច្ចពិគ្រោះយោបល់ដោយពិតប្រាកដដោយផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការវិភាគ និងមតិយោបល់ទៅលើសេចក្តីព្រាងនោះ ជាមួយភាគីពាក់ព័ន្ធនានារួមទាំងកម្មករនិយោជិត និងអង្គការសង្គមស៊ីវិល។
- បញ្ឈប់ការយាយីផ្នែកតុលាការទៅលើអ្នកការពារសិទ្ធិមនុស្ស សកម្មជននយោបាយ និងអ្នកនយោបាយគណបក្សប្រឆាំង និងដោះលែងជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌចំពោះអ្នកដែលជាប់ឃុំនាពេលថ្មីៗនេះដោយសារការចោទប្រកាន់ ឬការចាប់ខ្លួន ក្រោមហេតុផលនយោបាយដែលគ្មានមូលដ្ឋានច្បាប់ និងមិនគួរកើតមានក្នុងសង្គមប្រជាធិបតេយ្យបែបពហុបក្ស។
- ធានាថា ករណីយាយីប្រឆាំងទៅលើអ្នកសារព័ត៌មាន បុគ្គលិកអង្គការ សមាជិកសហជីព និងតួអង្គសង្គមស៊ីវិលផ្សេងទៀតត្រូវបានស៊ើបអង្កេតដោយត្រឹមត្រូវ ហើយត្រូវនាំយកជនដៃដល់ដោយមិនប្រកាន់ឋានៈមកផ្តន្ទាទោសចំពោះទង្វើរបស់ពួកគេនៅចំពោះមុខច្បាប់ ។
- ធានាថា មន្ត្រីកងយោធពលខេមរៈភូមិន្ទប្រកាន់គោលជំហរអព្យាក្រឹត្យចំពោះគណបក្សនយោបាយ និងមិនឲ្យមន្ត្រីយោធាមានតំណែងជាផ្លូវការនៅក្នុងគណបក្សនយោបាយណាមួយ។
- ធានាឲ្យមានការអនុវត្តន៍ទៅលើអនុសាសន៍ទាំងអស់ដែលបានលើកឡើងនៅក្នុងការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ទៅលើប្រទេសកម្ពុជា របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅឆ្នាំ២០១៤ ។

កំណត់ត្រាសង្ខេបនេះ តាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ជាអង្គការឈានមុខ មិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។ ព័ត៌មានលើកឡើងក្នុងកំណត់ត្រាសង្ខេបនេះ គឺ ផ្អែកតាមទិន្នន័យដែលប្រមូលបាន ឬបានផ្ទៀងផ្ទាត់ដោយ ម.ស.ម.ក។

## I. **ការការពារផ្នែកច្បាប់-សេរីភាពមូលដ្ឋាន**

មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញធានាថា ប្រជាពលរដ្ឋខ្មែរមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។[3] មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយដែលកម្ពុជាបានផ្តល់សច្ចាប័ននៅក្នុងឆ្នាំ១៩៩២ ក៏ការពារផង

[3] សូមមើលមាត្រា៤១ នៃរដ្ឋធម្មនុញ្ញ "*ប្រជាពលរដ្ឋខ្មែរមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ*"។

ដែរនូវសេរីភាពខាងការបញ្ចេញមតិ។[4] ប៉ុន្តែ ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា ត្រូវបានចាត់ចំណាត់ថ្នាក់ទី១៣៩ ក្នុងចំណោម១៨០ប្រទេស នៅក្នុងសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០១៥ របស់អ្នករាយការណ៍គ្មានព្រំដែន[5] ដែលនេះជាការគួរឱ្យបារម្ភ។ សេរីភាពខាងការបញ្ចេញមតិ បូករួមទាំងការទទួលបានសិទ្ធិសេរីភាពខាងការជួបប្រជុំ និងការបង្កើតសមាគម និងការអនុវត្តន៍សិទ្ធិបោះឆ្នោត។ ប្រជាពលរដ្ឋចូលរួមក្នុងកិច្ចការសាធារណៈតាមរយៈការពិភាក្សា និងកិច្ចសន្ទនាសាធារណៈជាមួយតំណាង ឬចូលរួមតាមសមត្ថភាពរបស់ខ្លួនក្នុងការរិះគន់ក្នុងន័យស្ថាបនា។ ការធានាសេរីភាពខាងការបញ្ចេញមតិ គឺពិតជាមានសារៈសំខាន់ចំពោះការចូលរួមតាមបែបលទ្ធិប្រជាធិបតេយ្យ។

សិទ្ធិសេរីភាពខាងការបង្កើតសមាគម មានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សចែងថា "*ជនគ្រប់រូបមានសិទ្ធិសេរីភាពខាងការប្រមូលផ្តុំដោយសន្តិវិធី និងសិទ្ធិបង្កើតសមាគម*" ចំណែកមាត្រា២៣ បញ្ជាក់ថា "*ជនគ្រប់រូបមានសិទ្ធិបង្កើត និងចូលរួមសហជីពដើម្បីការពារផលប្រយោជន៍របស់ខ្លួន*"។ មាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយលើកឡើងពីការរឹតត្បិតដែលអាចទទួលយកបានចំពោះសេរីភាពខាងការបង្កើតសមាគម ដោយចែងថា "*គ្មានការរឹតត្បិតណាអាចធ្វើឡើងលើការអនុវត្តន៍សិទ្ធិនេះ ដូចអ្វីដែលមានចែងនៅក្នុងច្បាប់ និងជាការចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យនូវផលប្រយោជន៍សន្តិសុខជាតិ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈឡើយ ដែលជាការការពារដល់សុខភាពសាធារណៈ ឬសីលធម៌ ឬជាការការពារដល់សិទ្ធិសេរីភាពរបស់បុគ្គលដទៃ*"។ រដ្ឋធម្មនុញ្ញកម្ពុជា ការពារផងដែរនូវសិទ្ធិបង្កើតសមាគមដូចមានចែងក្នុងមាត្រា៤២។ បើទោះជាមានការធានាទាំងនេះ សេរីភាពខាងការបង្កើតសមាគមនៅកម្ពុជាបានស្ថិតនៅក្រោមការវាយប្រហារជាទ្រង់ទ្រាយធំនៅប៉ុន្មានខែចុងក្រោយនេះ។

សិទ្ធិសេរីភាពខាងការប្រមូលផ្តុំ ក៏មានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនិងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ។ ម្យ៉ាងទៀត ច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ("ច្បាប់បាតុកម្ម") ចែងពីលក្ខខណ្ឌដើម្បីទទួលបានសិទ្ធិសេរីភាពខាងការប្រមូលផ្តុំ។ ច្បាប់នេះកំណត់ឲ្យការជួបប្រជុំ និងការហែក្បួនទាំងអស់នៅកម្ពុជាប្រព្រឹត្តទៅដោយសន្តិភាព លើកលែងតែការប្រមូលផ្តុំគ្នាដើម្បីធ្វើយុទ្ធនាការបោះឆ្នោត ការប្រមូលផ្តុំពាក់ព័ន្ធទៅនឹងវិវាទការងារ និងការជួបប្រជុំផ្សេងទៀតដែលជាការបម្រើដល់សាសនា សិល្បៈ វប្បធម៌ ប្រពៃណី និងទំនៀមទំលាប់ជាតិ និងសកម្មភាពផ្សព្វផ្សាយការអប់រំដើម្បីផលប្រយោជន៍សង្គមដូចជា វេទិកាសាធារណៈជាដើម។ ច្បាប់នេះចែងពីការជូនដំណឹងក្នុងរយៈពេលជាក់លាក់ និងតម្រូវឱ្យមានការបញ្ជាក់ពីគោលបំណង "*ព័ត៌មានច្បាស់លាស់*" ដែលជាការបង្ហាញថាបាតុកម្មនោះអាចបង្ក

[4] សូមមើលមាត្រា១៩ នៃ ក.អ.ស.ព.ន " *ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព ឬតាមទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃក្តី តាមការជ្រើសរើសរបស់ខ្លួន*"។

[5] អ្នករាយការណ៍គ្មានព្រំដែន សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោក ព័ត៌មានលម្អិតសូមចូលទៅកាន់តំណ ៖ https://index.rsf.org/#!/index-details/KHM។

គ្រោះថ្នាក់ ឬ ធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម ដែលជាមូលដ្ឋានក្នុងការបដិសេធ។ បទប្បញ្ញត្តិក្នុងច្បាប់នេះជាទូទៅស្របតាមបទដ្ឋានច្បាប់អន្តរជាតិ។ តែទោះជាយ៉ាងណា ច្បាប់បាតុកម្មត្រូវបានអនុវត្តដោយបំពានជារឿយៗ ដែលជាការធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងការប្រមូលផ្តុំ។ ជាការពិតណាស់ បើទោះជាមានការគោរពតាមលក្ខខណ្ឌនានានៃច្បាប់នេះក៏ដោយ គូបដិបក្ខនយោបាយ សកម្មជននៅតាមសហគមន៍មូលដ្ឋាន និងបាតុករជារឿយៗត្រូវបានរារាំងក្នុងការអនុវត្តសិទ្ធិប្រមូលផ្តុំដោយសន្តិវិធីរបស់ខ្លួន តាមរយៈការហាមប្រាមដោយទំនើងលើការប្រមូលផ្តុំ ការចាប់ខ្លួន និងការឃាំឃាំងផ្នែកតុលាការ។

## II. **ការរឹតត្បិតលើសេរីភាពមូលដ្ឋាន និងការគំរាមកំហែងចំពោះលទ្ធិប្រជាធិបតេយ្យ**

*"រាជរដ្ឋាភិបាលកម្ពុជាក៏បានប្តេជ្ញាមុតមាំផងដែរដើម្បីបង្ក្រាប ឬទប់ស្កាត់នូវរាល់សកម្មភាពទាំងអស់ និងកលល្បិចនានា ក្រោមការរូបភាពនៃលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ដើម្បីទទួលផលប្រយោជន៍នយោបាយផ្ទាល់ខ្លួន ឬជនមួយក្តាប់តូច"*។ នេះជាការលើកឡើងរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅទិវាសន្តិភាពអន្តរជាតិ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥។

## **ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល**

ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល("ច្បាប់សមាគមអង្គការ") ដែលទើបតែប្រកាសឱ្យអនុវត្តនាពេលថ្មីៗនេះគឺជាឧទាហរណ៍សំខាន់មួយទៀតដែលបង្ហាញពីនិន្នាការគួរឲ្យព្រួយបារម្ភទាក់ទិននឹងលំហលទ្ធិប្រជាធិតេយ្យរួមតូចនៅកម្ពុជា។

ចាប់តាំងពីមានការប្រកាសរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងខែមេសា ឆ្នាំ២០១៥ ឲ្យបន្តដំណើរការអនុម័តច្បាប់សមាគមអង្គការ អង្គការសង្គមស៊ីវិលជាច្រើន ការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ("អ.ស.ប") អ្នកជំនាញ អ.ស.ប សហភាពអឺរ៉ុប និងប្រតិភូទូតជាច្រើននៅកម្ពុជាបានសម្តែងការបារម្ភជាខ្លាំងចំពោះច្បាប់សមាគមអង្គការនេះ។ នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៥ ទីស្តីការគណៈរដ្ឋមន្ត្រីបានអនុម័តលើសេចក្តីព្រាងទីប្រាំនៃច្បាប់សមាគមអង្គការ។ បន្ទាប់ពីត្រូវបានសេចក្តីព្រាងច្បាប់ត្រូវបានកែប្រែតិចតួច សេចក្តីព្រាងច្បាប់នោះត្រូវបានបញ្ជូនទៅកាន់រដ្ឋសភានៅពាក់កណ្តាលខែមិថុនា។ កិច្ចពិគ្រោះយោបល់បង្គ្រប់កិច្ចមួយត្រូវបានធ្វើឡើងនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ក្រោមប្រធានបទស្តីពី "សិក្ខាសាលាថ្នាក់ជាតិស្វែងយល់អំពីច្បាប់អង្គការ សមាគម" ដែលមានតែក្តីបារម្ភតិចតួចប៉ុណ្ណោះត្រូវបានយកមកពិចារណា។ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ រដ្ឋសភាបានអនុម័តសេចក្តីព្រាងច្បាប់សមាគម អង្គការដោយមានការកែប្រែតិចតួច បើទោះបីជាគណបក្សប្រឆាំងធ្វើពហិកាចូលរួមនៅក្នុងសម័យប្រជុំសភា និងមានការអំពាវនាវជាច្រើនឱ្យបញ្ឈប់ដំណើរការអនុម័តច្បាប់ ដោយបើកឲ្យមានកិច្ចពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយតួអង្គពាក់ព័ន្ធ ឬច្រានចោលច្បាប់នោះយ៉ាងណាក៏ដោយ។ ច្បាប់សមាគម អង្គការត្រូវបានអនុម័តដោយព្រឹទ្ធសភានៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ ដោយពុំមានការពិភាក្សាបន្ថែម ហើយទីបំផុតត្រូវបានព្រះមហាក្សត្រឡាយព្រះហត្ថលេខាប្រកាសឱ្យអនុវត្តនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥។

ច្បាប់សមាគម អង្គការបានរំលោភទៅលើបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងកាតព្វកិច្ចច្បាប់អន្តរជាតិរបស់កម្ពុជាពាក់ព័ន្ធនឹងសេរីភាព មូលដ្ឋាន។ ច្បាប់នេះមានបទប្បញ្ញត្តិមួយចំនួនគួរឱ្យព្រួយបារម្ភខ្លាំងទាក់ទិននឹងការកំណត់អាណត្តិនៃការចុះបញ្ជីការ ហើយលក្ខខណ្ឌនៃការចុះបញ្ជីការមានលក្ខណៈស្មុគ្រស្មាញកាតព្វកិច្ចផ្ញើរបាយការណ៍ និងខ្លឹមសារទូលំទូលាយពេក និងមិនច្បាស់លាស់ចំពោះការបដិសេធការចុះបញ្ជី និងការចុះបញ្ជីឡើងវិញ។

ច្បាប់សមាគម អង្គការលើកឡើងពីចំណុចព្រួយបារម្ភយ៉ាងខ្លាំង មិនត្រឹមតែទៅលើអង្គការសង្គមស៊ីវិលជាតិប៉ុណ្ណោះទេ ប៉ុន្តែពាក់ព័ន្ធនឹងសមាគម និងអង្គការបរទេសដែលមានបំណងធ្វើប្រតិបត្តិការនៅកម្ពុជាផងដែរ។ ច្បាប់សមាគមអង្គការថ្មីនេះ ចែងពីអាណត្តិក្នុងការចុះបញ្ជីចំពោះសមាគម និងអង្គការទាំងអស់ មិនមែនតែដើម្បីឲ្យមានការទទួលស្គាល់ជានីតិបុគ្គលប៉ុណ្ណោះទេ ប៉ុន្តែក្នុងការធ្វើសកម្មភាពណាមួយក៏ដោយ។ ការហាមប្រាមអង្គភាពដែលមិនទាន់បានចុះបញ្ជីក្នុងការធ្វើសកម្មភាពណាមួយនោះ ដែលមិនសមស្របទៅនឹងសិទ្ធិសេរីភាពខាងការបង្កើតសមាគម ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិឡើយ។ សមាគម និងអង្គការជាតិត្រូវចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ ចំណែកអង្គភាពបរទេសត្រូវពិភាក្សា និងឯកភាពលើគម្រោងទាំងអស់ជាមួយ អាជ្ញាធរសាធារណៈដែលមិនបានបញ្ជាក់ពីសមាសភាព នៅមុនពេលដាក់សំណើចូលទៅក្នុងអនុស្សរណៈនៃការយោគយល់ជាមួយក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ បទប្បញ្ញត្តិទាំងនេះ អនុញ្ញាតឲ្យអាជ្ញាធរប្រើអំណាចជ្រៀតជ្រែកយ៉ាងខ្លាំងលើសកម្មភាពរបស់ពួកគេ។ ម្យ៉ាងទៀត ខ្លឹមសារនៃសេចក្តីព្រាងច្បាប់មានលក្ខណៈមិនច្បាស់ដែលធ្វើឲ្យមានការភាន់ច្រលំទាក់ទិននឹងការដាក់ពាក្យចុះបញ្ជីរបស់អង្គការនៅតាមសហគមន៍មូលដ្ឋាន និងចលនាពលរដ្ឋក្រៅផ្លូវការ។ ច្បាប់នោះមិនបានបង្ហាញឲ្យបានច្បាស់ពីការមិនរាប់បញ្ចូល សហគមន៍តាមមូលដ្ឋាន ដែលទុកចន្លោះប្រហោងសម្រាប់អាជ្ញាធរមូលដ្ឋានបកស្រាយថាតើគួររាប់បញ្ចូលនៅក្រោមរូបភាពសមាគមដែរឬទេ ។ ម.ស.ម.ក បានសរសេរលិខិតស្នើសុំការបំភ្លឺពីក្រសួងមហាផ្ទៃចំពោះបញ្ហានេះកាលពីថ្ងៃទី២១ ខែសីហា ឆ្នា២០១៥ ហើយក៏មានឆ្លើយតបពីក្រសួងនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥។[6] លិខិតឆ្លើយតបរបស់ក្រសួងបញ្ជាក់ថា ច្បាប់សមាគមអង្គការនឹងមិនត្រូវអនុវត្តន៍ចំពោះអង្គការសហគមន៍តាមមូលដ្ឋាន ប៉ុន្តែទោះជាយ៉ាងណា នៅតែមានភាពចន្លោះប្រហោងដែលអជ្ញាធរ និងមន្ត្រីតាមមូលដ្ឋានអនុវត្តន៍ខុសទៅនឹងច្បាប់ ដោយសារពាក្យពេចន៍មិនច្បាស់លាស់ដែលមានចែងនៅក្នុងច្បាប់។ ការអនុវត្តន៍ខុសប្រភេទនេះនឹងមានចងក្រងជាករណីសិក្សានៅក្នុងផ្នែកទី៣ ខាងក្រោម។

ច្បាប់ថ្មីនេះមិនបានចែងមូលន័យឲ្យបានច្បាស់អំពីបែបបទនៃការចុះបញ្ជីការដែលអាចត្រូវបានច្រាលចោលឡើយ។ រាល់សមាគម និងអង្គការទាំងអស់កំពុងតែប្រឈមនឹងការគំរាមបិទតាមអំពើចិត្ត ដោយសារតែមិនអនុលោមតាមលក្ខខណ្ឌដែលមានអត្ថន័យទូលំទូលាយនោះ។ ជាពិសេស ពាក្យពេចន៍បញ្ញត្តិមិនច្បាស់លាស់ដែលមានចែងក្នុងមាត្រា៨(៤) បានចែងថា ក្រសួងមហាផ្ទៃអាចបដិសេធរាល់សំណើចុះបញ្ជីរបស់

[6] លិខិតចំហ ស្នើការបញ្ជាក់អំពីការអនុវត្តន៍ច្បាប់ស្តីពីសមាគមអង្គការនៅថ្នាក់មូលដ្ឋាន និងក្រុមបណ្តាញក្រៅផ្លូវការ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ អាចស្វែងរកបានតាមរយៈតំណ http://bit.ly/1OU9Sp0។

សមាគម និងអង្គការក្នុងស្រុក ដែលគោលដៅ និងគោលបំណងរបស់ស្ថាប័នទាំងនោះអាចប៉ះពាល់ដល់សន្តិសុខសាធារណៈ ស្ថេរភាព និង សណ្តាប់ធ្នាប់ ឬបង្កឲ្យមានគំរាមគំហែងដល់សន្តិសុខជាតិ ឬ វប្បធម៌ ប្រពៃណី និងទំនៀមទំលាប់ល្អរបស់សង្គមជាតិកម្ពុជា។ មាត្រា ៨ បានផ្តល់អំណាចដល់ក្រសួងមហាផ្ទៃក្នុងការការពិនិត្យឯកសារសំណើនានារបស់សមាគម ឬអង្គការ ការស្នើសុំចុះបញ្ជីដើម្បីក្លាយជានីតិបុគ្គលតាមលក្ខខណ្ឌច្បាប់ និងផ្តល់សិទ្ធិសម្រេចលើសំណើនោះ។ បើទោះជាតម្រូវឱ្យក្រសួងមហាផ្ទៃ ធ្វើការជូនដំណឹងដល់អ្នកដាក់សំណើជាលាយលក្ខណ៍អក្សរនៃកំណែចាំបាច់ក្នុងសំណុំបែបបទក្តី សេចក្តីព្រាងច្បាប់នោះមិនតម្រូវឱ្យក្រសួងមហាផ្ទៃសរសេរជាលាយលក្ខណ៍អក្សរពីមូលហេតុ ទៅលើសេចក្តីសម្រេចចុងក្រោយ នោះឡើយ។ ដូច្នេះហើយ សំណុំបែបស្នើសុំ នោះនាំឱ្យមានការច្រានចោលដោយហេតុផលមិនច្បាស់លាស់។ មាត្រា៨ (៣) ចែងថា ក្នុងករណីធ្វើសេចក្តីសម្រេចយឺតយ៉ាវ (រហូតដល់ហួស ៤៥ ថ្ងៃនៃថ្ងៃការងារ) សមាគម ឬអង្គការ នឹងត្រូវចាត់ទុកថាបានចុះបញ្ជីដោយស្របច្បាប់ ហើយក្រសួងត្រូវតែធ្វើការលើឯកសារចុះបញ្ជី។ ទោះយ៉ាងណាក្តី នៅមានការបារម្ភពីការអនុវត្តន៍ជាក់ស្តែងនៃបទប្បញ្ញត្តិនេះ។ ជាពិសេស គួរមានការបញ្ជាក់ពីការទទួលស្គាល់នៅពេលមានការដាក់ជូននូវសំណុំបែបបទស្នើសុំ និងមុខងារត្រឹមត្រូវដើម្បីធ្វើប្រតិបត្តិការក្នុងករណីចុះបញ្ជីដោយស្វ័យប្រវត្តិ។

មាត្រា២៤ នៃច្បាប់សមាគមអង្គការក៏តម្រូវផងដែរ នូវការចុះបញ្ជីឡើងវិញឲ្យមានអព្យាក្រឹត្យភាពទាក់ទិននឹងគណបក្សនយោបាយសម្រាប់សមាគម និងអង្គការបរទេសទាំងអស់ព្រមទាំងអង្គការក្នុងស្រុកផងដែរ។ បទប្បញ្ញត្តិមិនច្បាស់នេះ មិនបានអនុវត្តចំពោះសមាគមក្នុងស្រុកឡើយ ដែលទុកឱកាសឱ្យមានការរំលោភបំពានធ្ងន់ធ្ងរដល់សេរីភាពខាងការបង្កើតសមាគម និងការរំលោភបំពានពីសំណាក់អាជ្ញាធរដើម្បីបំបិទសំឡេងគូបដិបក្ខ និងការរិះគន់។ ការព្យួរជាបណ្តោះអាសន្ន និងការលុបឈ្មោះអង្គការសង្គមស៊ីវិល ចេញពីបញ្ជីដោយសារតែមិនគោរពតាមលក្ខខណ្ឌក្នុងការធ្វើរបាយការណ៍ជាដើម អាចនឹងប្រឈមភាពគ្រោះថ្នាក់បន្ថែមទៀត។ ការព្យួរ ឬការលុបឈ្មោះដោយសារសកម្មភាពនានា ជាការផ្ទុយទៅនឹងច្បាប់ដែលនាំឱ្យមានការជ្រៀតជ្រែកដោយមិនចាំបាច់ទៅលើកិច្ចការរបស់សង្គមស៊ីវិល។ ជាចុងក្រោយក្នុងបទប្បញ្ញត្តិដែលមានការព្រួយបារម្ភខ្លាំង គឺ មាត្រា៣០ ដែលចែងថា ក្រសួងមហាផ្ទៃត្រូវលុបឈ្មោះអង្គការ និងសមាគមក្នុងស្រុកទាំងឡាយណាដែលធ្វើសកម្មភាពនាំឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខជាតិ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬប៉ះពាល់ដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់សង្គមជាតិចេញពីបញ្ជី នេះទុកចន្លោះប្រហោងផងដែរឲ្យមានលុបឈ្មោះសង្គមស៊ីវិលតាមអំពើចិត្ត។ បទប្បញ្ញត្តិស្រដៀងគ្នានេះគឺអនុវត្តចំពោះសមាគម និងអង្គការបរទេសផងដែរអនុលោមតាមបទប្បញ្ញត្តិមានចែងក្នុងមាត្រា៣៤ និងមាត្រា៣៥។ ការដាក់ទណ្ឌកម្មផ្នែករដ្ឋបាលដ៏ធ្ងន់ធ្ងរ ក៏ត្រូវបានធ្វើឡើងចំពោះសមាគម និងអង្គការទាំងឡាយណាដែលធ្វើសកម្មភាពនានាដោយមិនបានចុះបញ្ជី ឬបន្តសកម្មភាពរបស់ខ្លួនបើទោះជាមានការព្យួរ ឬលុបឈ្មោះចេញពីបញ្ជីក៏ដោយ។

ច្បាប់សមាគមអង្គការផ្តល់អំណាចយ៉ាងទូលំទូលាយទៅឱ្យរដ្ឋាភិបាល ដែលអាចអនុវត្តហួសដែនកំណត់ទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ សង្គមស៊ីវិលកម្ពុជា និងសហគមន៍អន្តរជាតិមួយចំនួនធំមានការព្រួបារម្ភជាខ្លាំងដោយសារតែច្បាប់សមាគមអង្គការដែលទើបតែអនុម័តនាពេលថ្មីៗនេះ នឹងត្រូវប្រើដើម្បីរឹតត្បិតជា

ខ្លាំងទៅលើសិទ្ធិសេរីភាពខាងការបង្កើតសមាគម និងគបសង្កត់ទៅលើសមត្ថភាពរបស់សង្គមស៊ីវិលប្រតិបត្តិការងារនៅកម្ពុជា។

## ច្បាប់បោះឆ្នោតដែលទើបតែអនុម័តថ្មីៗ នេះ

នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ("ច្បាប់បោះឆ្នោត") ត្រូវបានអនុម័តយ៉ាងប្រញាប់ប្រញាល់ និងមានដំណើរការមិនច្បាស់លាស់។ ច្បាប់កំណែទម្រង់ការបោះឆ្នោតទាំងនេះត្រូវបានព្រាងឡើងដោយគណបក្សនយោបាយធំៗចំនួនពីរ គឺគណបក្សប្រជាជនកម្ពុជា ("ប្រ.ជ") និងគណបក្សសង្គ្រោះជាតិ ("គ.ស.ជ") ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងនយោបាយរបស់ខ្លួនធ្វើឡើងនៅខែកក្កដា ឆ្នាំ២០១៤។ ច្បាប់នេះតាក់តែងឡើងដោយគ្មានធ្វើការពិគ្រោះយោបល់ជាសាធារណៈជាមួយសង្គមស៊ីវិលឡើយ បើទោះជាមានលិខិតអញ្ជើញអង្គការសង្គមស៊ីវិលឱ្យចូលរួមក្នុងសិក្ខាសាលា តែរយៈពេលពីរបីថ្ងៃប៉ុណ្ណោះ មុនការអនុម័តច្បាប់នោះ។

ច្បាប់បោះឆ្នោតថ្មី រឹតត្បិតជាខ្លាំងលើសេរីភាពខាងការបញ្ចេញមតិ ជាពិសេសក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោត ព្រមទាំងមិនបានបង្កើតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយឯករាជ្យពិតប្រាកដមួយ ("គ.ជ.ប")។ បទប្បញ្ញត្តិមួយចំនួនមានខ្លឹមសារមិនច្បាស់លាស់ ដែលចែងពីទោសនានាទាក់ទិននឹងការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងសកម្មភាពពាក់ព័ន្ធនឹងនយោបាយក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោត នៅពេលបោះឆ្នោត និងពេលរាប់សន្លឹកឆ្នោត ដោយកាត់បន្ថយនូវតួនាទីរបស់សង្គមស៊ីវិលក្នុងការឃ្លាំមើលការបោះឆ្នោត និងសកម្មភាពផ្សេងៗទៀតពាក់ព័ន្ធនឹងការបោះឆ្នោត។

ជាពិសេស មាត្រា៨៤ និង១៣៧ នៃច្បាប់បោះឆ្នោត កំណត់ឱ្យអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងសមាគមទាំងអស់រក្សាគោលជំហរអព្យាក្រឹត្យ និងមិនលម្អៀង។ មាត្រា៨៤ ហាមប្រាមធ្វើសកម្មភាពជាច្រើនទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីពាក់ព័ន្ធក្នុងការឃោសនាបោះឆ្នោតរួមមាន "*ការចេញផ្សាយសេចក្តីថ្លែងការណ៍ ឬការធ្វើសកម្មភាពណាមួយមានគោលបំណងគាំទ្រ ឬបង្ហាញពីភាពលម្អៀង ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់*"។ ជាការឲ្យនិយមន័យផ្ទុយពីច្បាប់ថា "*ព្រះញាត់*" ហើយអាជ្ញាធរអាចបកស្រាយចំពោះក្រុមអ្នកសង្កេតការណ៍ដែលបញ្ចេញយោបល់ទៅលើការបោះឆ្នោតថា ជាការរំលោភលើលក្ខខណ្ឌមិនលម្អៀង និងអព្យាក្រឹត្យ។ ការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិដូចក្នុងមាត្រា៨៥ផងដែរ ដែលហាមប្រាម "*ជនបរទេស*" ក្នុងការឱ្យធ្វើសកម្មភាព "*ដោយផ្ទាល់ ឬដោយប្រយោលក្នុងយុទ្ធនាការបោះឆ្នោតដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់*"។ ជនបរទេសជាច្រើនពាន់នាក់ត្រូវបានអនុញ្ញាតឱ្យរស់នៅ និងធ្វើការងារនៅកម្ពុជា។ ជនបរទេសជាង ២៥,០០០នាក់ ត្រូវបានផ្តល់ប័ណ្ណ

អនុញ្ញាតការងារនៅពាក់កណ្តាលឆមាសដំបូងក្នុងឆ្នាំ២០១៥[7] ហើយមានជនស្នាក់នៅស្របច្បាប់កាន់តែច្រើនត្រូវបានប៉ាន់ប្រមាណថាធ្វើការងារ ប៉ុន្តែមានការអនុញ្ញាតជាផ្លូវការ។ បន្ថែមលើនេះ រដ្ឋាភិបាលមានផែនការទទួលជនភៀសខ្លួនជាច្រើន ហើយនៅពេលថ្មីៗនេះបានផ្តួចផ្តើមដាក់ចេញគោលនយោបាយទទួលយកជនភៀសខ្លួនពីរដ្ឋាភិបាលប្រទេសអូស្ត្រាលី។ កម្ពុជាក៏ជាទីកន្លែងជ្រកកោនសម្រាប់ជនគ្មានលិខិតស្នាម និងគ្មានអត្តសញ្ញាណជាតិត្រឹមត្រូវរហូតដល់ចំនួន៣០០០០០ ក្នុងចំណោមប្រជាជនខ្មែរក្រោមប្រមាណ១លាននាក់ដែលគេជឿថា នៅតែពុំទាន់មានលិខិតស្នាមត្រឹមត្រូវនៅឡើយទេ។

មាត្រា១៦០ នៃច្បាប់បោះឆ្នោតបន្ថែមថា ភ្នាក់ងារសង្កេតការណ៍បោះឆ្នោតរបស់ភាគីគណបក្សនយោបាយ និងអង្គការ ក៏ត្រូវតែមានជំហរអព្យាក្រឹត្យផងដែរ ហើយមិនអាចបង្គាប់បញ្ជា ឬរំខានដល់មន្ត្រីរៀបចំការបោះឆ្នោតបានឡើយ ក្នុងអំឡុងពេលសង្កេតការបោះឆ្នោត។ មាត្រានេះលើកឡើងថា ការព្រមានជាលាយលក្ខណ៍អក្សរ ព្រមទាំងផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) ដល់ ១០.០០០.០០០(ដប់លាន) រៀល នឹងត្រូវអនុវត្តចំពោះ *"ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត"*។ ចំណុចនេះនឹងគាបសង្កត់ទៅលើសមត្ថកិច្ចរបស់អ្នកសង្កេតការណ៍ក្នុងការរិះគន់សកម្មភាពរបស់សមាជិករបស់គណបក្សនយោបាយ កងទ័ព កងរាជអាវុធហត្ថ ឬមន្ត្រីផ្សេងទៀតដែលធ្វើសកម្មភាពលម្មៀង ឬប្រព្រឹត្តអំពើហិង្សាពាក់ព័ន្ធនឹងការបោះឆ្នោត។

ខណៈដែលសមត្ថភាពរបស់សង្គមស៊ីវិលក្នុងអំឡុងពេលបោះឆ្នោតនឹងប្រឈមការរឹតបន្តឹង មាត្រា៨៣ នៃច្បាប់បោះឆ្នោតអនុញ្ញាតឲ្យកងកម្លាំងសន្តិសុខ និងមន្ត្រីតុលាការចូលរួមក្នុងសកម្មភាពយុទ្ធនាការបោះឆ្នោតជាការគាំទ្រដល់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់នៅក្រៅម៉ោងការងារ។ មាត្រា១២៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថាៈ *"អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការជានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ"*។ ប៉ុន្តែ បទប្បញ្ញត្តិនៃច្បាប់បោះនេះបានអនុញ្ញាតឱ្យមន្ត្រីតុលាការធ្វើសកម្មភាពក្នុងនាមជាសមាជិកបក្ខ។ កាន់តែគួរឱ្យព្រួយបារម្ភទៅទៀតនោះ ច្បាប់នេះបើកឱកាសផងដែរដល់មន្ត្រីយោធាធ្វើសកម្មភាពគំរាមកំហែងក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោត។ គួរពិចារណាផងដែរក្នុងករណីដែលគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ដាក់បញ្ចូលសមាសភាពមេបញ្ជាការកងយោធពលខេមរៈភូមិន្ទ បទប្បញ្ញត្តិនេះត្រូវបានគេមើលឃើញថា ជាការគំរាមកំហែងពិតប្រាដកដល់ការប្រព្រឹត្តទៅនៃការបោះឆ្នោតដោយសេរី និងដោយសន្តិភាព។

មាត្រា ១៥២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចែងថា *"ត្រូវពិន័យចំពោះជនណាដែលប្រើគ្រប់មធ្យោបាយ ដើម្បីប្រមាថជាសាធារណៈចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬញុះញង់ឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃ*

[7] ពេជ្រ សុធារី "រដ្ឋាភិបាលផ្តល់ប័ណ្ណអនុញ្ញាតការងារដល់ជនបរទេសចំនួន២៥,០០០នាក់" *កាសែតភ្នំពេញប៉ុស្តិ៍* ថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ២០១៥ អាចស្វែងរកតាមរយៈតំណ ៖http://www.phnompenhpost.com/national/permitted-more-25000-get-work-cards។

*សាសនាណាមួយជាកំណត់ នៅក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត*"។[8] មាត្រា១៦២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របន្ថែមថា "*អំពើល្មើសដែលប្រព្រឹត្តដោយគណបក្សនយោបាយ គឺជាអំពើល្មើសប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍គណបក្សនយោបាយនោះ ដូច្នេះជាការដាក់ទោសទណ្ឌលើគណបក្សទាំងស្រុងចំពោះបទល្មើសប្រព្រឹត្តដោយបុគ្គលជាសមាជិកបក្ស*។ ទោសទណ្ឌនឹងរាប់បញ្ចូលទាំងការលុបឈ្មោះគណបក្សនោះផងដែរ។

ខណៈដែលសេរីភាពខាងការបញ្ចេញមតិ ការប្រមូលផ្តុំ និងការបង្កើតសមាគម គឺជាលក្ខខណ្ឌសំខាន់សម្រាប់ការអនុវត្តន៍សិទ្ធិបោះឆ្នោតប្រកបដោយប្រសិទ្ធភាព ហើយត្រូវតែទទួលការការពារយ៉ាងពេញលេញ នោះច្បាប់បោះឆ្នោតនេះ រឹតត្បិតហួសហេតុទៅលើសិទ្ធិមូលដ្ឋានទាំងនេះ ដោយរំលោភទៅលើបទដ្ឋានអន្តរជាតិ និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា៣៥ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា ប្រជាពលរដ្ឋកម្ពុជាមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ។ ប្រជាពលរដ្ឋទាំងអស់ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាល និងសមាគម ដូច្នេះគួរតែត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងកិច្ចពិភាក្សាជាសាធារណៈ ក្នុងនោះរួមទាំងការអនុវត្តន៍សេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិនយោបាយក្នុងអំឡុងពេលបោះឆ្នោតផងដែរ។

## សេចក្តីព្រាងច្បាប់ស្តីពីសហជីព

សេចក្តីព្រាងច្បាប់ស្តីពីសហជីពត្រូវបានដាក់ចេញដោយរដ្ឋាភិបាលលើកដំបូងនៅឆ្នាំ២០១១ ប៉ុន្តែត្រូវបានផ្អាកវិញ បន្ទាប់ពីក្រុមសង្គមស៊ីវិល និងសហជីពបានលើកឡើងកង្វល់នានា ក្នុងនោះរួមមាន (១) ច្បាប់នោះនឹងធ្វើឱ្យសហជីពងាយរងនឹងការរំលាយ និងការចុះបញ្ជីការឡើងវិញ (២)ច្បាប់នេះផ្តល់ភាពស្មុគ្រស្មាញ និងលក្ខខណ្ឌរើសអើងចំពោះបុគ្គលដែលមានបំណងធ្វើជាថ្នាក់ដឹកនាំក្នុងសហជីពដូចជា តម្រូវឱ្យមានលិខិតថ្កោលទោស (ជាពិសេស សកម្មជនសហជីពដែលជារឿយៗប្រឈមនឹងបណ្តឹងព្រហ្មទណ្ឌ) និង (៣) ផ្តល់លទ្ធភាពដល់រដ្ឋាភិបាលខ្លាំងពេកលើការធ្វើសេចក្តីសម្រេចក្នុងចំណុចទាំងនេះ ដែលនាំឱ្យមានការកាត់បន្ថយសិទ្ធិសេរីភាពខាងការបង្កើតសមាគមរបស់កម្មករនិយោជិត។

សេចក្តីព្រាងច្បាប់ថ្មីមួយត្រូវបានចេញផ្សាយនៅក្នុងខែតុលា ឆ្នាំ២០១៤ ដោយមិនបានរាប់បញ្ចូលកម្មករក្នុងស្រុក និងកម្មករផ្សេងទៀតក្នុងបណ្តាញសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងការបង្កើតសហជីព។ ច្បាប់នេះក៏កំណត់ផងដែរពីចំនួនអប្បបរិមា២០%នៃកម្មករនិយោជិតដើម្បីបង្កើតសហជីព ដែលធ្វើឱ្យមានការលំបាកខ្លាំងក្នុងការបង្កើតសហជីពឯករាជ្យ។ យោងតាមសេចក្តីប្រកាសមិនផ្លូវការនាពេលថ្មីៗនេះ ចំណុចនេះបានកាត់បន្ថយចំនួនមនុស្សដែលអាចបង្កើតសហជីពបានមកត្រឹមតែ១០នាក់ នៅក្នុងសេចក្តីព្រាងច្បាប់ចុងក្រោយដែលមិន

[8] គណៈកម្មាធិការសិទ្ធិមនុស្សរបស់ អ.ស.ប បានថ្លែងថា ក្នុងបរិបទនៃការពិភាក្សាផ្នែកនយោបាយជាសាធារណៈ "ករណីនោះគ្រាន់តែជាទម្រង់នៃការបញ្ចេញមតិដែលមិនត្រូវចាត់ថាជាការញុះញង់ទៅលើមន្ត្រីសាធារណៈនោះទេ ដូច្នេះមិនមានជាតុផ្សំគ្រប់គ្រាន់ដើម្បីផ្តល់យុត្តិកម្មក្នុងការកំណត់ទោសឡើយ" សូមមើលវិចារណៈកថាទូទៅលេខ ៣៤ មាត្រា១៩ ៖ សេរីភាពគំនិត និងការបញ្ចេញមតិ ក.អ.ស.ព.ន/គ/វិចារណៈកថាទូទៅ/៣៤(ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១)។

បានចេញផ្សាយ។[9] សេចក្តីព្រាងច្បាប់ឆ្នាំ២០១៤ ផ្តល់អំណាចដល់ក្រសួងការងារមានសិទ្ធិព្យួរសហជីពដែលចូលរួមក្នុងសកម្មភាពជាមួយក្រុមដែលចាត់ទុកជាការ *"ធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ច"* ឬធ្វើឱ្យ *"ប៉ះពាល់"* ដល់ផលប្រយោជន៍ជាតិ ដែលជាការកំហិតសេរីភាពខាងការបង្កើតសមាគម តាមរយៈការអនុវត្តតាមពាក្យដែលមានន័យទូលំទូលាយ និងមិនច្បាស់លាស់។

សេចក្តីព្រាងច្បាប់ស្តីពីសហជីពនៅតែស្ថិតនៅឆ្ងាយពី លិខិតូបករណ៍ស្តីពីសិទ្ធិការងារអន្តរជាតិ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នរួមមាន អនុសញ្ញាលេខ៨៧របស់អង្គការពលកម្មអន្តរជាតិ ("អាយឡូ") ស្តីពីសេរីភាពខាងការបង្កើតសមាគម និងអនុសញ្ញាលេខ៩៨ស្តីពីសិទ្ធិរៀបចំ និងការចរចារួម។ បន្ថែមពីនេះសេចក្តីព្រាងច្បាប់នេះនឹងរំលោភទៅលើមាត្រា៣៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលចែងថា ប្រជាពលរដ្ឋខ្មែរនឹងមានសិទ្ធិ *"បង្កើត និងក្លាយជាសមាជិករបស់សហជីព"* និងមាត្រា៣៧ ជានាសិទ្ធិធ្វើកូដកម្ម និងចូលរួមក្នុងការធ្វើបាតុកម្មអហិង្សា។ ម្យ៉ាងទៀត ច្បាប់នេះនឹងបំពានផងដែរលើមាត្រា២៦៦ នៃច្បាប់ស្តីពីការងារដែលចែងថា កម្មករ និងនិយោជិតមានសិទ្ធិបង្កើតអង្គការវិជ្ជាជីវៈក្នុងគោលបំណងសិក្សា លើកកម្ពស់ផលប្រយោជន៍ និងការពារសិទ្ធិបុគ្គលគ្រប់ដណ្តប់ដោយលក្ខន្តិកៈរបស់ស្ថាប័ន។

ទោះបីមានការព្រួយបារម្ភទាំងនេះ រដ្ឋាភិបាលបានប្តេជ្ញាអនុម័តច្បាប់នោះនៅចុងឆ្នាំ២០១៥។ ស្ថានភាពបច្ចុប្បន្ននៃច្បាប់នេះមិនប្រាកដ ហើយសេចក្តីព្រាងចុងក្រោយមិនទាន់ត្រូវបានបង្ហាញជាសាធារណៈនៅឡើយ ដែលផ្ទុយទៅនឹងគោលការណ៍តម្លាភាព និងអភិបាលកិច្ចតាមបែបលទ្ធិប្រជាធិបតេយ្យ។

## សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាដែលមិនបានចាំង

ក្នុងខែឧសភា ឆ្នាំ២០១២ រដ្ឋាភិបាលប្រកាសពីគោលបំណងរបស់ខ្លួនក្នុងការអនុម័ត *"ច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា"* ជាលើកដំបូង ក្នុងគោលបំណងគ្រប់គ្រងមាតិកាលើបណ្តាញអ៊ីនធឺណិត និងដើម្បីរារាំង *"ក្រុមអាក្រក់"* ក្នុងការចែកចាយព័ត៌មានមិនពិត។[10] ទោះបីសង្គមស៊ីវិលព្យាយាមស្នើសុំសេចក្តីព្រាងច្បាប់ថតចម្លងពីសំណាក់រដ្ឋាភិបាលយ៉ាងណាក្តី ក៏រដ្ឋាភិបាលមិនមានឆន្ទៈឆ្លើយតបឲ្យបានច្បាស់លាស់នោះទេ។ បន្ទាប់មកសេចក្តីព្រាងច្បាប់នោះបានលេចធ្លាយនៅខែមេសា ឆ្នាំ២០១៤ ប៉ុន្តែរដ្ឋាភិបាលបានបដិសេធចេញផ្សាយជាសាធារណៈនូវសេចក្តីព្រាងផ្លូវការ។ ជាការឆ្លើយតប ម.ស.ក.ក បានសរសេរលិខិតផ្ញើរជូនរដ្ឋមន្ត្រីប្រៃសណីយ៍ និងទូរគមនាគមន៍ សម្តែងក្តីបារម្ភទាក់ទិននឹងសេចក្តីស្នើច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា។[11] នៅចុងឆ្នាំ២០១៤នេះដែរ អង្គភាពព័ត៌មាន និងប្រតិកម្មរហ័សនៃទីស្តីការគណៈរដ្ឋមន្ត្រីបានប្រកាសពី

---

[9] Zsombor Peter អង្គការILO លើកឡើងថាសេចក្តីព្រាងច្បាប់ស្តីពីសហជីពចុងក្រោយមានភាពល្អប្រសើរ" កាសែត *ឌឹ ខេមបូឌាដេលី* ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៥ អាចស្វែងរកបានតាមរយៈតំណ ៖ https://www.cambodiadaily.com/news/ilo-says-latest-draft-law-on-trade-union-an-improvement-93690/។

[10] កម្ពុជាធ្វើច្បាប់គ្រប់គ្រងអ៊ីនធឺណិតធ្វើឲ្យមានការបារម្ភការរឹតត្បិត កាសែតភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ អាចស្វែងរកបានតាមរយៈតំណ ៖ http://bit.ly/1Jrl1GP។

[11] អ្នកស្រី ចក់ សុភាព "លិខិតចំហរបស់ ម.ស.ម.ក សម្តែងការបារម្ភអំពីសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា" ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤។

ការបង្កើត "*ក្រុមការងារប្រព័ន្ធផ្សព្វផ្សាយសង្គម*"[12]ក្នុងគោលបំណងតាមដាននូវរាល់សកម្មភាពនៅលើបណ្តាញអ៊ីនធឺណិត ដើម្បី "*ការពារគោលជំហ និងកិត្យានុភាពរបស់រដ្ឋាភិបាល*" ខណៈដែលក្រសួងមហាផ្ទៃបានប្រកាសថា ខ្លួននឹងតម្លើងឧបករណ៍តាមដានគ្រប់បណ្តាញទូរស័ព្ទនៅកម្ពុជា និងក្រុមហ៊ុនផ្តល់សេវាអ៊ីធឺណិតទាំងអស់។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤ អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី លោក ផៃ ស៊ីផាន បានថ្លែងថា សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាដ៏ចម្រូងចម្រាស់ត្រូវបាន "*លុបចោល*" ព្រោះនេះមិនមែនជា "ការងារអត្ថិភាព" នោះទេ។[13] ជាការគួរឱ្យព្រួយបារម្ភ រដ្ឋាភិបាលហាក់ដូចជាផ្តល់អត្ថិភាពទៅលើច្បាប់នោះ។ នៅចុងខែឧសភា ឆ្នាំ២០១៥ រដ្ឋមន្ត្រីប្រៃសណីយ៍ និងទូរគមនាគមន៍បានប្រកាសថា ច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាកំពុងស្ថិតនៅក្នុងការពិនិត្យ និងថា ច្បាប់នោះនឹងចាត់ជាបទល្មើសព្រហ្មទណ្ឌចំពោះ "*បុគ្គលដែលមានចេតនាទុច្ចរិត*" ដែល "*រិះគន់រដ្ឋាភិបាល*"។[14]

សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាដែលចម្រូងចម្រាស់ មានបទប្បញ្ញត្តិជាច្រើនអាចរឹតត្បិតយ៉ាងធ្ងន់ធ្ងរលើសេរីភាពខាងការបញ្ចេញមតិនៅលើបណ្តាញអ៊ីនធឺណិត ប្រសិនបើច្បាប់នេះត្រូវបានអនុម័ត និងទំនងជានាំឲ្យមានការចាប់ពិរុទ្ធខ្លួនឯង។ ម.ស.ម.ក បានលើកឡើងកង្វល់នានាកាលពីដំបូងទាក់ទិនផលប៉ះពាល់ដែលអាចកើតឡើងលើសេរីភាពខាងការបញ្ចេញមតិ។[15]

ក្នុងនោះក្តីបារម្ភសំខាន់គឺ មាត្រា២៨ ដែលហាមប្រាមការផ្សព្វផ្សាយខ្លឹមសារ ឬផ្សាយបន្តព័ត៌មានមិនពិត និងចែងពីទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់យ៉ាងធ្ងន់ធ្ងរ។ បទប្បញ្ញត្តិដែលជាបញ្ហាបំផុត ក្នុងចំណោមបទប្បញ្ញត្តិមួយចំនួននោះ មានចេតនាហាមប្រាមផ្សព្វផ្សាយខ្លឹមសារដែលបណ្តាលឱ្យមាន "*អសន្តិសុខ អសុវត្ថិភាព និងអស្ថិរភាពផ្នែកនយោបាយ*" (មាត្រា២៨(៣)) ឬផ្សព្វផ្សាយខ្លឹមសារអ្វីដែលធ្វើឱ្យប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គមជាតិ" ជាអាទិ៍ "*ការមួលបង្កាច់ បរិហារកេរ្តិ៍ និងការជេរប្រមាថ*" (មាត្រា២៨(៥)(គ))។ បទប្បញ្ញត្តិមានខ្លឹមសារមិនច្បាស់លាស់ទាំងនេះផ្តល់ឥទ្ធិពលហួសហេតុដល់រដ្ឋាភិបាលក្នុងការកំណត់លើប្រភេទមាតិកាដែលប៉ះពាល់ដល់កិត្តិយរបស់ខ្លួន។ ខ្លឹមសារដែលនឹងត្រូវបានបង្កើតឡើងនោះ គួរតែត្រូវបានពន្យល់ឱ្យបានល្អិតល្អន់ និងមានខ្លឹមសារច្បាស់លាស់ ដើម្បីបញ្ចៀសការបកស្រាយដោយបំពាន។ម្យ៉ាងវិញទៀត ការរឹតត្បិតទៅលើខ្លឹមសារ គួរតែធ្វើឡើងក្នុងកាលៈទេសៈពិសេស និងចាំបាច់បំផុតតែប៉ុណ្ណោះ។

---

[12] កាសែត ឌឹ ខេមបូឌាដេលី "ក្រុមការងារប្រព័ន្ធផ្សព្វផ្សាយសង្គម" ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ អាចស្វែងរកតាមរយៈតំណ ៖ http://www.cambodiadailykhmer.com/news/20726/។

[13] កាសែត ឌឹ ខេមបូឌាដេលី រដ្ឋាភិបាលថា "សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសតាមអ៊ីនធើណិតត្រូវបាន "លុបចោល" ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៤ អាចស្វែងរកបានតាមរយៈតំណ ៖ http://www.cambodiadailykhmer.com/news/21202/។

[14] ក្រសួងលើកឡើងថា "ច្បាប់ស្តីពីបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាការពារកិត្តយសរបស់រដ្ឋាភិបាល" កាសែត *ឌឹខេមបូឌា ដេលី* ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ អាចស្វែងរកតាមរយៈតំណ ៖ https://www.cambodiadaily.com/news/cyber-law-to-protect-govt-honor-ministry-says-84431/។

[15] កំណត់ត្រាសង្ខេប របស់ ម.ស.ម.ក " ច្បាប់អ៊ីនធឺណិត ៖ តើជាឧបករណ៍ការពារ ឬរឹតបន្តឹងសេរីភាពបញ្ចេញមតិ?" ខែកុម្ភៈ ឆ្នាំ២០១៤)។ អាចស្វែងរកបានតាមតំណ
http://www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=51&id=5។

ម្យ៉ាងទៀត មាត្រា២៨ (៤) ដែលហាមប្រាមផ្សព្វផ្សាយខ្លឹមសារព័ត៌មានដែល *"ជាការប្រមាថមើលងាយដល់ស្ថាប័នជាតិ"* អាចធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់សង្គមស៊ីវិលដើម្បីតាមដានសកម្មភាពរបស់រដ្ឋាភិបាល ដែលមានតួនាទីសំខាន់ក្នុងការលើកកម្ពស់លទ្ធិប្រជាធិតេយ្យ ព្រមទាំងជាការបំបិទសំឡេងសកម្មជន និងគណបក្សនយោបាយ។ ជាងនេះទៀត មាត្រា ៣៥ រាប់បញ្ចូល *"ការលើលែងចោល"* ដែលជាទោសបន្ទាប់បន្សំសម្រាប់នីតិបុគ្គល ដែលរាប់បញ្ចូលទាំងអង្គការសង្គមស៊ីវិល ដែលប្រព្រឹត្តបទល្មើសក្រោមមាត្រា ២១ ដល់មាត្រា៣២ និងជាការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិដោយពុំត្រឹមត្រូវ។

ជាចុងក្រោយ មានការដាក់បញ្ចូលនូវមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលក្នុងគណៈកម្មាធិការជាតិប្រឆាំងនឹងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា ("គ.ប.ប.") ដែលបានចែងក្នុងមាត្រា៦ ដែលនេះនឹងមិននាំទៅរកការបង្កើតស្ថាប័នត្រួតពិនិត្យដោយឯករាជ្យចំពោះការប្រើប្រាស់អ៊ីនធឺណិតឡើយ។ តែផ្ទុយទៅវិញ ប្រសិនបើច្បាប់ស្តីពីឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យាត្រូវបានរដ្ឋាភិបាលដាក់ចេញ ច្បាប់នោះគួរតែចែងពីការបង្កើតក្រុមការងារឯករាជ្យដោយរួមមានសមាសភាពពីអ្នកជំនាញបច្ចេកទេស សមាជិកនៃអង្គការសង្គមស៊ីវិល អ្នកសិក្សាស្រាវជ្រាវដើម្បីស៊ើបអង្កេត និងធ្វើការវិភាគមាតិកាព័ត៌មានឱ្យបានត្រឹមត្រូវនៅមុនពេលធ្វើការចោទប្រកាន់ ឬទប់ស្កាត់សំណើ និងនៅមុនពេលសំណើនានាត្រូវបានបញ្ជូនបន្តទៅកាន់តុលាការ។

## សេចក្តីព្រាងច្បាប់ស្តីពីទូរគមនាគមន៍

ជាចុងក្រោយ មានការបារម្ភថា ការព្យាយាមបង្កើតសេចក្តីព្រាងច្បាប់ស្តីពីទូរគមនាគមន៍ នឹងបង្កើនការគ្រប់គ្រងរបស់រដ្ឋាភិបាលទៅលើឧស្សាហកម្ម និងជាការគំរាមបន្ថែមទៀតដល់សេរីភាពខាងការបញ្ចេញមតិ។

យោងតាមឯកសារបកប្រែក្រៅផ្លូវការពីឆ្នាំ២០១៤ បង្ហាញថា សេចក្តីព្រាងច្បាប់នោះមានបទប្បញ្ញត្តិមួយចំនួន មានខ្លឹមសារមិនច្បាស់លាស់ ដែលចែងពីទោសដាក់ពន្ធនាគារយ៉ាងធ្ងន់ធ្ងរ និងមិនសមាមាត្រចំពោះប្រជាពលរដ្ឋដែលត្រូវបានរកឃើញថាប្រើប្រាស់បណ្តាញទូរគមនាគមន៍ដើម្បីធ្វើការគំរាមកំហែង ឬអុចអាលនាំឱ្យប្រព្រឹត្តបទឧក្រិដ្ឋ។ ទោសមានចែងក្នុងជំពូក៨ ពិន័យជាប្រាក់ចាប់ពី២៥០០ដុល្លា រហូតដល់១,២លានដុល្លា និងអនុវត្តទោសជាប់ពន្ធនាគាររយៈពេលចន្លោះពី១សប្តាហ៍ ដល់១៥ឆ្នាំ។ លើសពីនេះទៅទៀតនោះក្រសួងប្រៃសណីយ៍និងទូរគមនាគន៍នឹងមានសិទ្ធិបង្គាប់ឱ្យក្រុមហ៊ុនផ្តល់សេវាពាក់ព័ន្ធនឹងទូរគមនាគមន៍ប្រគល់ទិន្នន័យ ប្រព័ន្ធ និងឧបករណ៍នានា ឬបញ្ជូនប្រព័ន្ធត្រួតពិនិត្យផ្នែកទូរគមនាគមន៍ទៅកាន់ក្រសួង ក្នុងគោលបំណងដើម្បី *"ផលប្រយោជន៍ជាតិ សន្តិសុខ ស្ថិរភាព និងបណ្តាប់ធ្នាប់សាធារណៈ"*។

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ ក្រសួងប្រៃសណីយ៍ និងទូរគមនាគន៍ និងនាយកដ្ឋាននគរបាលជាតិបានរួមគ្នាប្រកាសថាមកដល់ថ្ងៃទី២៣ ខែកញ្ញា ច្បាប់ថ្មីនឹងចូលជាធរមានដែលតម្រូវឲ្យក្រុមហ៊ុនផ្តល់សេវាមានភារកិច្ចផ្តល់ព័ត៌មានពីអត្តសញ្ញាណលម្អិតរបស់អ្នកប្រើប្រាស់ស៊ីមកាតទូរស័ព្ទនៅកម្ពុជា ទាំងអស់ទៅឲ្យនគរ

បាល។ អ្នកលក់ចែកចាយដែលគោរពតាមច្បាប់នេះនឹងត្រូវដាក់ទោសព្រហ្មទណ្ឌ។[16]

ជាមួយគ្នានេះមានការបង្កើតបណ្ដាញទូរគមនាគមន៍នានា ជាធម្មតាពុំបង្កឲ្យមានជាបញ្ហាក្នុងប្រទេសឡើយ តែជាការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សយ៉ាងពិតប្រាកដ ប៉ុន្តែសេចក្តីព្រាងច្បាប់នេះទុកឱកាសច្រើនពេកសម្រាប់ការបកស្រាយ និងអាចត្រូវបានគេប្រើប្រាស់បន្ថែមដើម្បីរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ។

## សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធទទួលព័ត៌មាន

សិទ្ធិទទួលព័ត៌មានជាសាធារណៈ មិនមែនជាសិទ្ធិដោយឡែកពីសេរីភាពខាងការបញ្ចេញមតិនោះទេ សិទ្ធិទទួលព័ត៌មានគឺជាស្នូលនៃលទ្ធិប្រជាធិបតេយ្យ។ មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា "*សិទ្ធិសេរីភាពខាងការបញ្ចេញមតិ រាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង*"។

ចាប់តាំងពីឆ្នាំ២០០១ អង្គការមិនមែនរដ្ឋាភិបាលធ្វើការនៅកម្ពុជាបានជំរុញឱ្យមានតម្លាភាពកាន់តែប្រសើរ និងការបង្រៀនពីសិទ្ធិតាមបែបលទ្ធិប្រជាធិបតេយ្យ ដែលជាការលើកកម្ពស់ការអនុវត្តន៍សិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិបានខិតខំប្រឹងប្រែងជំរុញឱ្យបើកចំហដល់សាធារណៈជនអាចទទួលព័ត៌មានជាសាធារណៈតាមរយៈការជួយសម្រួលឱ្យមានកំណើននៃការប្រើប្រាស់អ៊ីធឺណិត។ ជាលទ្ធផលនៃកិច្ចប្រឹងប្រែងរបស់ក្រុមអង្គការសង្គមស៊ីវិល សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានត្រូវបានបញ្ជូនទៅកាន់រដ្ឋសភានៅឆ្នាំ២០១០ និងសេចក្តីព្រាងច្បាប់វិសោធនកម្ម ត្រូវបានបញ្ជូនទៅកាន់រដ្ឋសភាឆ្នាំ២០១២។ ប៉ុន្តែសេចក្តីព្រាងច្បាប់ទាំងពីរនោះត្រូវបានច្រានចោលវិញ។ ទោះបីមានការចូលរួមជាវិជ្ជមានមួយចំនួនពីសំណាក់សង្គមស៊ីវិលជាមួយរដ្ឋាភិបាល ចាប់ពីពេលបង្ហាញច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន រហូតមកដល់ពេលនេះកម្ពុជាមិនទាន់អនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននៅឡើយទេ។

កង្វះការទទួលបានព័ត៌មានគ្រប់គ្រាន់ និងមិនលម្អៀងបានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ការបង្កើត និងចែករំលែកគំនិតយោបល់ដោយសេរី។ ករណីនេះនៅតែជាឧបសគ្គដ៏ធំមួយសម្រាប់សង្គមស៊ីវិល និងបណ្តាញព័ត៌មាននានា ដែលមានបំណងធ្វើការងារឃ្លាំមើលលទ្ធិប្រជាធិបតេយ្យ។ ជាពិសេស កង្វះប្រភពព័ត៌មានគ្រប់គ្រាន់ ជាការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធភាពរបស់អ្នកសារព័ត៌មាន និងសង្គមស៊ីវិលក្នុងការផ្តល់ព័ត៌មាន និងជំរុញឱ្យមានកិច្ចពិភាក្សា។ ការបង្កើនការទទួលបានព័ត៌មានជាសាធារណៈតាមរយៈការបង្កើតច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដែលប្រសើរ នឹងនាំឱ្យប្រជាពលរដ្ឋកម្ពុជាអនុវត្តសិទ្ធិតាមបែបលទ្ធិប្រជាធិបតេយ្យ ដើម្បីចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេច និងសេរីភាពខាងការបញ្ចេញមតិ។ ច្បាប់នេះក៏នឹងផ្តល់ព័ត៌មានសំខាន់ៗ ដល់

---

16 "អ្នកទិញស៊ីមទូរស័ព្ទគ្មានអត្តសញ្ញាណប័ណ្ណនឹងត្រូវកាត់ផ្តាច់" កាសែតភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥អាចស្វែងរកបានតាមរយៈតំណ http://www.phnompenhpost.com/national/sim-card-crackdown។

ប្រជាពលរដ្ឋដើម្បីធ្វើសេចក្តីសម្រេចអំពីបញ្ហាដែលប៉ះពាល់ ដែលនេះជាការលើកកម្ពស់តម្លាភាព និងគណនេយ្យភាពរបស់បុគ្គល និងស្ថាប័នដែលគ្រប់គ្រងអំណាចនៅកម្ពុជា។

លទ្ធិប្រជាធិបតេយ្យតម្រូវឱ្យមានភាពជាពលរដ្ឋ និងភាពជាអ្នកដឹកនាំដែលមានការទទួលខុសត្រូវខ្ពស់។ សម្រាប់គោលបំណងទាំងនេះ អាចសម្រេចទៅបាន លុះត្រាតែសិទ្ធិដឹងឮជាសាធារណៈ ត្រូវបានគេការពារ និងប្រតិបត្តិខ្ជាប់ខ្ជួនតាមច្បាប់ និងអនុវត្តដោយសកម្មនូវគោលការណ៍សេរីភាពទទួលបានព័ត៌មាន។

នៅឆ្នាំ២០១៤ រដ្ឋាភិបាលកម្ពុជាបានទទួលយកអនុសាសន៍នៃការត្រួតពិនិត្យជាសាកលតាមកាលកំណត់ដោយជំរុញឲ្យប្រទេសកម្ពុជាបង្កើតច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ដែលជាធាតុដ៏សំខាន់នៃសេរីភាពខាងគំនិត និងការបញ្ចេញមតិ។[17] ដំណាក់នានាបានឆ្ពោះទៅរកការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន និងគោលនយោបាយ កំពុងតែធ្វើដំណើរទៅមុខ រួមទាំងមានកិច្ចសហការពីក្រសួងព័ត៌មាន អង្គការយូនីស្កូ និងសង្គមស៊ីវិលផងដែរ។ ដោយមានការសង្ឃឹមថា ដំណាក់កាលទាំងនេះអាចនាំទៅរកកំណែទម្រង់ពិតប្រាកដក្នុងការទទួលបានព័ត៌មានសម្រាប់សង្គមស៊ីវិល និងប្រជាពលរដ្ឋកម្ពុជាទូទៅ។

## យោធាមានទំនាក់ទំនងស្អិតរមួតជាមួយគណបក្សប្រជាជនកម្ពុជា

ក្រៅពីការរំលោភបំពានតាមរយៈច្បាប់ជាច្រើនពីសំណាក់រាជរដ្ឋាភិបាល ទៅលើសេរីភាពខាងការបញ្ចេញមតិ ការប្រមូលផ្តុំ និងការបង្កើតសមាគម ការគំរាមកំហែងធ្ងន់ធ្ងរបន្ថែមទៀតចំពោះលទ្ធិប្រជាធិតេយ្យនៅកម្ពុជាកើតមានឡើងតាមរយៈការកើនឡើងនូវភក្តីភាពរបស់កងយោធពលខេមរៈភូមិន្ទចំពោះគណបក្សប្រជាជនកម្ពុជា(“ប្រ.ជ”) កំពុងគ្រប់គ្រងអំណាច។

ដូចបានពិភាក្សាក្រោមការវិភាគច្បាប់បោះឆ្នោតខាងលើ គណៈកម្មការកណ្តាលរបស់ ប្រ.ជ (ដែលជាស្ថាប័ននីតិប្រតិបត្តិខ្ពស់បំផុតរបស់គណបក្ស) មានចំនួនមន្ត្រីយោធាជាន់ខ្ពស់ជាច្រើននាក់ជាសមាជិក រួមមាន អគ្គមេបញ្ជាការកងយោធពលខេមរៈភូមិន្ទបច្ចុប្បន្ន អតីតមេបញ្ជា និងមេបញ្ជាការរង និងឧត្តមសេនីយផ្កាយ៤ជាច្រើននាក់ទៀត។ នៅក្នុងមហាសន្និបាតគណបក្សប្រចាំឆ្នាំ ក្នុងខែកុម្ភៈ ឆ្នាំ២០១៥ ប្រ.ជ បានបញ្ចូលសមាជិកថ្មីចំនួន ៣០៦ រូបបន្ថែមទៀតទៅក្នុងសមាជិកកណ្តាលគណបក្ស ក្នុងចំនួននេះក៏មានមន្ត្រីយោធា ៨០ នាក់ផងដែរ។ ទំនាក់ទំនងរវាង ប្រ.ជ និងកងយោធពលខេមរៈភូមិន្ទ មិនមែនជារឿងថ្មីឡើយ ប៉ុន្តែទំនាក់ទំនងជិតស្និទ្ធនេះបានដើរតាមលំនាំពីអតីតកាលគឺនៅពេលចាប់ផ្តើមឡើងគ្រប់គ្រងអំណាចរបស់លោក ហ៊ុន សែន ក្នុងឆ្នាំ១៩៨៥។ បន្ថែមទៅលើអង្គភាពយោធាដ៏រឹងមាំ កងយោធពលខេមរៈភូមិន្ទ ក៏មានកងរាជអាវុធហត្ថ និងអង្គភាពកងអង្គរក្សនាយករដ្ឋមន្ត្រីផងដែរ ដែលជាកងកម្លាំងប្រដាប់អាវុធមានភក្តីភាពចំពោះ

[17] ក្រុមប្រឹក្សាសិទ្ធិមនុស្ស របាយការណ៍របស់ក្រុមប្រឹក្សាការងារ ទទួលបន្ទុកការត្រួតពិនិត្យជាសាកលតាមកាលកំណត់ (ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤) អនុសាសន៍១១៨.១៧ អាចស្វែងរកនៅលើគេទំព័រដោយចូលតាមរយៈ http://daccess-dds-ny.un.org/doc/UNDOC/GEN/G14/127/27/PDF/G1412727.pdf?OpenElement។

លោក ហ៊ុន សែន ដែលមានសមាសភាពយោធា និងសមាជិកអង្គរក្សច្រើនរហូតចំនួន ១០,០០០នាក់។[18] អង្គភាពកងអង្គរក្សត្រូវបានបង្កើតឡើងនៅមុនពេលការធ្វើរដ្ឋប្រហារសហនាយករដ្ឋមន្ត្រីសម្តេច នរោត្តម រណឫទ្ធិ ក្នុងឆ្នាំ១៩៩៧ ដោយលោក ហ៊ុន សែន បានដណ្តើមអំណាចបន្ទាប់ពីកងអង្គរក្សរបស់លោកយកឈ្នះទាហានរបស់ទ្រង់ រណឫទ្ធិ។

ដោយទទួលបានផលប្រយោជន៍ពីការគ្រប់គ្រងអំណាចរយៈពេល៣០ឆ្នាំកន្លងមកនេះរបស់ប្រ.ជ មន្ត្រីជាន់ខ្ពស់យោធាជាច្រើនបានលះបង់ជាច្រើនដែលគួរតែជាអន្តរកាលនៃការផ្ទេរអំណាចធ្វើឡើងនៅកម្ពុជា។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រ.ជ បានផ្សាភ្ជាប់នូវទំនាក់ទំនងគួរឱ្យគ្រោះថ្នាក់ជាមួយកងយោធពលខេមរភូមិន្ទតាមមធ្យោបាយផ្សេងៗ ជាពិសេសនោះតាមរយៈការបង្កើនឱ្យមានកងកម្លាំងប្រដាប់អាវុធនានា ការបង្កើតភាពជាដៃគូផ្លូវការរវាងកងយោធពលខេមរភូមិន្ទ ជាមួយក្រុមហ៊ុនឯកជនជាដើម។ នៅថ្ងៃទី២៩ខែកក្កដា ឆ្នាំ២០១៥ កងយោធពលខេមរភូមិន្ទ បានប្រារព្ធខួបគម្រប់១០ឆ្នាំក្នុងភាពជាដៃគូនេះ នៅពេលនោះ រដ្ឋមន្ត្រីការពារជាតិ លោក ទា បាញ់ បានពន្យល់ជាពាក្យសាមញ្ញថា *"ក្រុមហ៊ុនឯកជនជាច្រើនបានផ្តល់ប្រាក់ឱ្យកងទ័ពដើម្បីទិញសព្វាវុធ"*[19] អ្នកឧបត្ថម្ភទាំងនោះរួមមាន ឧកញ៉ាក្នុងស្រុក និងអ្នកវិនិយោគបរទេសមួយចំនួន ដូចជាលោកឧញ៉ា ទ្រី ភាព ឈ្មួញរកស៊ីឈើដ៏ធំ ក្រុមហ៊ុនសហព័ន្ធរបស់ប្រទេសចិន ដែលបានផ្តល់ការឧបត្ថម្ភដល់អង្គភាពកងអង្គរក្សជាដើម។ ទំនាក់ទំនងរវាងក្រុមហ៊ុនសាជីវកម្មជាមួយយោធា ដែលធ្វើឡើងដោយ ប្រ.ជ គ្រប់គ្រងអំណាចនេះ បង្កការគំរាមធ្ងន់ធ្ងរមួយទៀតដល់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា និងជាការក្រើនរំលឹកថាប្រាក់ជាច្រើនសន្ធឹកសន្ធាប់ និងសព្វាវុធនៅកម្ពុជាទាំងអស់នោះគឺសម្រាប់តែការពារ ប្រ.ជ ឱ្យស្ថិតនៅក្នុងអំណាចតែប៉ុណ្ណោះ បើទោះជាធ្វើឡើងក្នុងមធ្យោបាយបែបណាក៏ដោយ។

ការសង្កេតឃើញទាំងនេះ ស៊ីសង្វាក់គ្នាជាមួយនឹងការថ្លែងនាពេលថ្មីនេះពីសំណាក់ថ្នាក់ដឹកនាំយោធា និងថ្នាក់ដឹកនាំនយោបាយដែលកាន់តែធ្វើឲ្យមានការចាប់អារម្មណ៍ថា អន្តរកាលនៃការផ្ទេរអំណាចដោយសន្តិវិធីស្ថិតនៅឆ្ងាយពីការរំពឹងទុក បើទោះជាគណបក្សជំទាស់អាចនឹងទទួលបានជ័យជម្នះក្នុងការបោះឆ្នោតថ្នាក់ជាតិក្នុងឆ្នាំ២០១៨ នោះក៏ដោយ។ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ ឧត្តមសេនីយផ្កាយ៤ ជា តារា បានថ្លែងសុន្ទរកថាចំពោះមុខមន្ត្រីយោធានៅវិមានសន្តិភាពថា *"ខ្ញុំសូមនិយាយដោយស្មោះត្រង់ថា កងទ័ពជារបស់គណបក្សប្រជាជនកម្ពុជា"*។[20] ទោះបីជាក្រោយមក ប្រ.ជ បានដកខ្លួនចេញពីការលើកឡើងនេះ តែយ៉ាងណាទាំងនេះជាការបង្ហាញឱ្យឃើញពីទំនាក់ទំនងរវាង ប្រ.ជ និងកងទ័ព។ ក្នុងសុន្ទរកថានេះដដែល លោក ជា តារា បានថ្លែងបន្ថែមថា នោះជាតួនាទីរបស់កងទ័ពដើម្បីបង្ក្រាបការធ្វើ *"បដិវត្តន៍ពណ៌"* ដែលជាការប្រឆាំងរដ្ឋាភិបា

---

[18] ខេវិន ដួយលី "លោកហ៊ុន សែន បុរសខ្លាំងកម្ពុជា" ថ្ងៃទី១ ខែមករាឆ្នាំ ២០១៤។ អាចស្វែងរកបានតាមរយៈ ៖ http://www.aljazeera.com/indepth/features/2014/01/challenging-cambodia-strongman-hun-sen-20141184836510703.html >។

[19] វង្ស សុខេង និង Kevin Doyle "សម្ព័ន្ធភាពយោធា និងឯកជនគឺជាគម្រោងជោគជ័យ" *កាសែតភ្នំពេញប៉ុស្តិ៍* ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ អាចស្វែងរកតាមរយៈតំណ http://bit.ly/1LSiCdm ។

[20] ដូសៅ លីប៉េស "*កងទ័ព ជារបស់គណបក្សប្រជាជនកម្ពុជា* មើលសិទ្ធិ" វិទ្យុអាស៊ីសេរី ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥។

ល ដោយសំដៅទៅលើចលនាអហិង្សាជាច្រើនដែលធ្វើការតស៊ូមតិដើម្បីលទ្ធិប្រជាធិបតេយ្យ និងកំណែទម្រង់សង្គម ដែលបានកើតឡើងនៅក្នុងអតីតសហភាពសូវៀត។ ការលើកឡើងរបស់ឧត្តមសេនីយរូបនេះ បានធ្វើឱ្យនាយករដ្ឋមន្ត្រី ហ៊ុន សែន លើកឡើងម្តងទៀតនៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៥ ដែលបានថ្លែងថា "*កងយោធពលខេមរៈភូមិន្ទត្រូវតែប្រុងប្រយ័ត្នចំពោះសកម្មភាពបដិវត្តន៍ពណ៌ និងមិនត្រូវឲ្យវាកើតឡើងបានទេ" យើងនឹងចាត់វិធានការភ្លាមៗចំពោះក្រុមណាមួយដែលធ្វើឲ្យប្រទេសជាតិធ្លាក់ក្នុងសង្គ្រាម"*។ [21] ជាងនេះទៅទៀត ថ្មីៗនេះនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ នាយករដ្ឋមន្ត្រីបានថ្លែងម្តងទៀតតាមការផ្សាយផ្ទាល់នៅលើកញ្ចក់ទូរទស្សន៍ថា "*ប្រទេសនឹងមានសង្គ្រាម ប្រសិនបើ ប្រ.ជ មិនដឹកនាំប្រទេស* "។[22] នៅក្នុងកិច្ចប្រជុំដែលមានការចូលរួមពីសំណាក់អ្នកជំនួញល្បីៗជាងគេនៅកម្ពុជានៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ មកនេះ លោក ហ៊ុន សែនបានប្រមានថាបើគ.ស.ជ ឈ្នះអាសនៈក្នុងការបោះឆ្នោត ប្រទេសអាចនឹងកើតមានសង្គ្រាមស៊ីវិល ដោយសារគោលនយោបាយរបស់គណបក្សប្រឆាំងផ្ទុយទៅនឹងផលប្រយោជន៍របស់អ្នកជំនួញធំៗ។ លោកថ្លែងថា "*ខ្ញុំហ៊ាននិយាយថាអ្នកនៅទីនេះសុទ្ធតែជាសត្រូវរបស់បក្សប្រឆាំង [គ.ស.ជ] អញ្ចឹងវាអាចមានសន្តិភាពម៉េចបាន...? តើសេដ្ឋីទាំងនេះសុទ្ធតែជាសត្រូវរបស់បក្សប្រឆាំង?"*[23]

ជារឿយៗ លោក ហ៊ុន សែន បានលើកឡើងនូវហេតុការណ៍ដែលអាចនាំឲ្យមានអំពើហិង្សា តាមរយៈសុន្ទរកថាជាសាធារណៈនានា ក្នុងអំឡុងពេលកាន់អំណាចរបស់លោក ដោយធ្វើការព្រមាននានាដែលនេះអាចធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់អារម្មណ៍ប្រជាពលរដ្ឋដែលមិនទាន់បានធូរស្បើយនៃអំឡុងពេលជម្លោះបង្ហូរឈាមផងនោះ។ ប៉ុន្តែក្នុងបរិបទនៃផ្លាស់ប្តូរទាំងស្រុងដោយរដ្ឋាភិបាល ឆ្ពោះទៅរកការបង្ក្រាបទៅលើសេរីភាពមូលដ្ឋាន និងលំហប្រជាធិបតេយ្យ ដែលការលើកឡើងទាំងនេះហាក់ដូចជាការគំរាមកំហែង។

### III **សសរស្តម្ភនៃលទ្ធិប្រជាធិបតេយ្យ**

ស្ថានភាពទូទៅនៃសំឡេងរិះគន់ និងឯករាជ្យ ដែលរងការគំរាមកំហែងកំពុងកើនឡើងនៅក្នុងប្រទេសកម្ពុជា។ នៅឆ្នាំ២០១៤ អ្នកសារព័ត៌មានម្នាក់នៅខេត្តក្រចេះបានក្លាយជាអ្នកសារព័ត៌មានទី១៣ ដែលត្រូវបានសម្លាប់នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៤ខណៈពេលព្យាយាមរាយការណ៍អំពីការកាប់ឈើខុសច្បាប់។ នៅកម្ពុជា សមាជិកគណបក្សប្រឆាំង បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងសកម្មជនផ្សេងទៀតបន្តរងការគំរាម និងការយាយីពីសំណាក់អាជ្ញាធរមូលដ្ឋាន និងបុគ្គលឯកជនដែលមានអំណាច ដោយសារអនុវត្តការងាររបស់គេ។ ការយាយីតាមផ្លូវតុលាការ រួមមានទាំងការបំពានតាម

[21] វង្ស សុខេង នាយករដ្ឋមន្ត្រីលើកឡើងថា "តួនាទីកងទ័ពគឺដើម្បីជួយរដ្ឋាភិបាល" កាសែត *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ព័ត៌មានបន្ថែមសូមចូលទៅកាន់តំណ៖ http://www.phnompenhpost.com/militarys-role-help-government-pm-says។
[22] គុច ណារ៉េន "លោក ហ៊ុន សែន មានប្រសាសន៍ការពារកិច្ចការព្រំដែន ហើយព្រមានគណបក្សសង្គ្រោះជាតិ" កាសែត *ឌឹ ខេមបូឌាដេលី* ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥។ ព័ត៌មានបន្ថែមសូមស្វែងរករយៈតំណ៖ http://www.cambodiadailykhmer.com/news/27465/។
[23] កង សុធា និង អេឡិក វិល្លីមមីនស៍ "លោក ហ៊ុន សែន ថា គោលនយោបាយដីធ្លីរបស់គណបក្សសង្គ្រោះជាតិនឹងបណ្តាលឲ្យមានសង្គ្រាម" កាសែត *ឌឹ ខេមបូឌា ដេលី* ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ អាចស្វែងរកបានតាមរយៈតំណ៖ http://www.cambodiadailykhmer.com/news/27714/។

រយៈការចោទប្រកាន់ព្រហ្មទណ្ឌ និងការបំពានដោយការឃុំខ្លួនបណ្ដោះអាសន្ន នៅតែជាក្ដីបារម្ភ និងជាឧបសគ្គសម្រាប់សង្គមស៊ីវិលឯករាជ្យ និងការប្រឆាំងផ្នែកនយោបាយ។ ស្ថានភាពនេះកាន់តែអាក្រក់ឡើងក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ។ ករណីខាងក្រោមពន្យល់ពីលំហដែលសំឡេងជំទាស់កំពុងតែរួមតូច ។

## ការប្រឆាំងផ្នែកនយោបាយ

បន្ទាប់ពីការប្រកាសលទ្ធផលដ៏រន្ធត់ក្រោយការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៣ ដែលគណបក្សសង្គ្រោះជាតិកម្ពុជា ("គ.ស.ជ") ទទួលបានអាសនៈចំនួន៥៥ កិច្ចព្រមព្រៀងនយោបាយដ៏ផុយស្រួយរវាងគណបក្សធំៗទាំងពីរហាក់ឈានទៅរកការប្រេះឆា។ *"វប្បធម៌សន្ទនា"* ដែលត្រូវបានបង្កើតឡើងបន្ទាប់ពីការធ្វើពហិការសភា របស់ គ.ស.ជ ដែលបានជំទាស់ទៅនឹងលទ្ធផលនៃការបោះឆ្នោត និងបានចោទប្រកាន់រដ្ឋាភិបាលថាបានបន្លំសន្លឹកឆ្នោត។ បន្ទាប់ពីមានការសន្យាជាថ្នូរនឹងការបង្កើតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មីមួយក្នុងចំណោមបញ្ហាជាច្រើនផ្សេងទៀតនោះ គ.ស.ជ បានយល់ព្រមចូលរដ្ឋសភានៅខែសីហា ឆ្នាំ២០១៤ ហើយមេដឹកនាំគណបក្សទាំងពីរ គឺ លោក ហ៊ុន សែន និងលោក សម រង្ស៊ី បានសន្យាបង្កើនកិច្ចសហប្រតិបត្តិការបន្ថែមទៀត តែទោះជាយ៉ាងណាទំនាក់ទំនងនោះមានភាពរកាំរកូសតិចតួចផងដែរ។ វប្បធម៌សន្ទនានេះជាញឹកញាប់បង្ហាញពីទំនាក់ទំនងកាន់តែប្រសើរឡើង ប៉ុន្តែព្រឹត្តិការណ៍ថ្មីៗកន្លងមកនេះបានធ្វើឲ្យទំនាក់ទំនងនេះមានកំរិត។ ការចាប់ខ្លួន និងផ្ដន្ទាទោសជាបន្តបន្ទាប់ និងដោយហេតុផលនយោបាយទៅលើសកម្មជន គ.ស.ជ និងអ្នកនយោបាយដែលមានការរៀបចំជាមុនរបស់រដ្ឋាភិបាល បានធ្វើឱ្យលេចឡើងនូវសំនួរជាច្រើនពាក់ព័ន្ធនឹងលទ្ធភាពនៃវប្បធម៌សន្ទនា និងស្ថានភាពការបោះឆ្នោតដោយសន្តិភាព សេរី និងយុត្តិធម៌នៅឆ្នាំ២០១៧ និងឆ្នាំ២០១៨។ ករណីសិក្សាខាងក្រោមបង្ហាញនូវនិន្នាការដែលគួរឱ្យព្រួយបារម្ភទាំងនេះ។

*ករណីសិក្សា ៖សមាជិកព្រឹទ្ធសភាគណបក្សប្រឆាំងជាប់ពន្ធនាគារដោយសារការបង្ហោះអត្ថបទនៅលើទំព័រហ្វេសប៊ុក*

កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ លោក ហុង សុខហួរ សមាជិកព្រឹទ្ធសភាគណបក្សសម រង្ស៊ី ត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារព្រៃស បន្ទាប់ពីត្រូវបានចោទប្រកាន់ពីបទក្លែងបន្លំឯកសារសាធារណៈ ប្រើប្រាស់ឯកសារក្លែងក្លាយ និងបទញុះញង់ឲ្យបង្កចលាចលដល់សណ្ដាប់ធ្នាប់សង្គមតាមមាត្រា ៦២៩ មាត្រា៦៣០ និងមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ។

លោក សុខហួរ ដែលមានអភ័យឯកសិទ្ធិការពារខ្លួនរួចផុតពីការចាប់ ការឃុំខ្លួន និងការចោទប្រកាន់នោះ ត្រូវបានចាប់ខ្លួនដោយកងកម្លាំងនគរបាលប្រដាប់ដោយកាំភ្លើង។ ការចាប់ខ្លួននេះធ្វើឡើងតែរយៈពេលបីថ្ងៃប៉ុណ្ណោះបន្ទាប់ពីសុន្ទរកថារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន អំពាវនាវឲ្យចាប់ខ្លួនលោកជាបន្ទាន់ពីបទ *"ក្បត់ជាតិ"* បន្ទាប់ពីសមាជិកព្រឹទ្ធសភារូបនេះបានបង្ហោះវីដេអូមួយនៅលើបណ្ដាញហ្វេសប៊ុក ដែលមានបញ្ចូលអត្ថបទសន្ធិសញ្ញាព្រំដែនក្លែងក្លាយឆ្នាំ១៩៧៩ រវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលវៀតណាម។

មាត្រា១០៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិរួចផុតពីការចោទប្រកាន់ ការចាប់ និងឃុំខ្លួនដោយសារការសម្ដែងមតិនៅក្នុងតួនាទីជាសមាជិកព្រឹទ្ធសភា។ យោងទៅលើរដ្ឋធម្មនុញ្ញ អភ័យឯកសិទ្ធិនេះអាចធ្វើការដកហូតបានលុះត្រាតែមានសំឡេងភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភា ប៉ុន្តែព្រឹត្តិការណ៍នោះមិនបានធ្វើឡើងនៅមុនពេលចាប់ខ្លួនសមាជិកព្រឹទ្ធសភាលោក សុខហួរ នោះទេ។ ករណីលើកលែងតែមួយគត់ដែលអាចធ្វើបានគឺចំពោះបទល្មើស*"ជាក់ស្ដែង"* ដែលជនដៃដល់ត្រូវបានចាប់ខ្លួនពេលកំពុងប្រព្រឹត្តបទល្មើស។ ករណីលើកលែងត្រូវបានក្រមស៊ើបសួរលោក កៅ វណ្ណិ

បង្កើតជាយុត្តិកម្មផ្លូវច្បាប់សម្រាប់ចាប់ខ្លួនលើសមាជិកព្រឹទ្ធសភារូបនេះ។ ប៉ុន្តែដាក់ស្តែងការចាប់ខ្លួននោះបានធ្វើឡើងរយៈពេលបីថ្ងៃបន្ទាប់ពីវីដេអូនោះត្រូវបានបង្ហោះជាលើកដំបូង និងបន្ទាប់ពីមានការអត្ថាធិប្បាយពីនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបង្ហាញយ៉ាងច្បាស់ថា ករណីនេះមិនមែនជាបទល្មើសជាក់ស្តែងនោះទេ។

ម្យ៉ាងវិញទៀតមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌចែងថា ការញុះញង់ឱ្យមានបទល្មើសបង្កចលាចលដល់សណ្តាប់ធ្នាប់សង្គមទាមទារឱ្យមានសកម្មភាពញុះញង់ "*ដោយផ្ទាល់*"។ ចំណែកករណីនេះពុំមែនជាការទទួលខុសត្រូវរបស់សមាជិកព្រឹទ្ធសភាលោក សុខហួរ ក្នុងការចេញផ្សាយសន្ធិសញ្ញាក្លែងក្លាយឡើយ នោះបញ្ជាក់យ៉ាងច្បាស់ថា ករណីនេះពុំអាចចាត់ទុកថាជាអំពើញុះញង់ជនណាម្នាក់ឲ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋនោះឡើយ។ ការក្លែងបន្លំនេះមានពន្យល់នៅក្នុងមាត្រា ៦២៦ នៃក្រមព្រហ្មទណ្ឌថា "*ការក្លែងបន្លំ*"។ មាត្រា ៦២៩ ចែងថា បទក្លែងបន្លំឯកសារសាធារណៈទាក់ទិនតែនឹង "*លិខិតយថាភូតត*" ឬឯកសារ "*ដែលចេញដោយរាជការសាធារណៈដើម្បីធ្វើការកត់សម្គាល់សិទ្ធិ អត្តសញ្ញាណ ឬឋានៈ ឬដើម្បីយល់ព្រមផ្តល់ការអនុញ្ញាត*"។ នៅក្នុងបរិបទនេះ ពុំមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីចោទប្រកាន់គាត់ពីបទក្លែងឯកសារឡើយ ដោយសារពុំមានភស្តុតាងដែលបញ្ជាក់ថា សមាជិកព្រឹទ្ធសភារូបនោះបានបង្កើតសន្ធិសញ្ញាក្លែងក្លាយនោះទេ ។

ការចាប់ខ្លួនផ្ទុយពីរដ្ឋធម្មនុញ្ញដូចនេះ គឺនៅចំពេលដែលមានសំណើក្រោមហេតុផលនយោបាយ ធ្វើឡើងក្នុងបរិបទវាយប្រហារដោយប្រយោល និងជាប្រព័ន្ធទៅលើសំឡេងប្រឆាំង និងសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។ មន្ត្រីរបស់ គ.ស.ជ បីរូបផ្សេងទៀតបានភៀសខ្លួនតាមប្រទេសថៃទៅកាន់ប្រទេសទីបីដើម្បីស្វែងរកសិទ្ធិជ្រកកោន ខណៈមានបារម្ភពីការចាប់ខ្លួនដោយសារការជួយបង្ហោះសន្ធិសញ្ញានោះ។

***ករណីសិក្សា ៖ សមាជិកសភាគណបក្សប្រឆាំងត្រូវបានហាមចូលរដ្ឋសភា***

កាលពីនៅខែកក្កដា សមាជិករដ្ឋសភារបស់គណបក្សប្រឆាំងលោក អ៊ុំ សំអាន ត្រូវបានហាមចូលរួមក្នុងកិច្ចប្រជុំរដ្ឋសភាលើកទី១៥ ហើយប្រាក់បៀវត្សរ៍របស់លោក២ខែ ត្រូវបានកាត់ដោយសារបាន"*ប្រមាថ*" ទៅលើប្រធានរដ្ឋសភាសម្តេច ហេង សំរិន។ អភ័យសិទ្ធិស្របច្បាប់របស់លោក អ៊ុំ សំអាន ត្រូវបានព្យួរ ដោយសារបានរិះគន់ប្រធានរដ្ឋសភា និងចោទប្រធានរដ្ឋសភាពីបទរំលោភរដ្ឋធម្មនុញ្ញ ដោយសារសម្តេចបដិសេធបញ្ជូនលិខិតស្តីពីដំណើរការវាស់វែងព្រំប្រទល់ប្រទេសវៀតណាម ទៅនាយករដ្ឋមន្ត្រី ហ៊ុន សែន។ មតិយោបល់របស់លោកត្រូវបានបង្ហោះនៅលើបណ្តាញផ្សព្វផ្សាយសង្គម ដោយស្នើឱ្យមានការពន្យល់ពីការបដិសេ ធបញ្ជូនលិខិតនោះ ហើយករណីនេះត្រូវបានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាចាត់ទុកថា ជាការរំលោភទៅលើមាត្រា៨៧ នៃរដ្ឋធម្មនុញ្ញ មាត្រា៥ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការ និងមាត្រា៧៧ និងមាត្រា៧៨ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។ នៅក្នុងឯកសារដែលចុះហត្ថលេខាដោយប្រធានរដ្ឋសភាសម្តេច ហេង សំរិន ដោយផ្ទាល់លើកឡើងថា មតិនោះធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់សម្តេច និងរដ្ឋសភាទាំងមូល។ បទបញ្ជានោះបានចេញតែរយៈពេលប៉ុន្មានថ្ងៃប៉ុណ្ណោះ បន្ទាប់ពីលោក អ៊ុំ សំអាន និងសមាជិករដ្ឋសភាបីរូបផ្សេងទៀតរបស់ គ.ស.ជ បានប្រមូលផ្តុំមនុស្សចុះទៅព្រំដែនវៀតណាមដែលមានជម្លោះ ក្នុងខេត្តស្វាយរៀង។

***ករណីសិក្សា ៖ សកម្មជនគណបក្សសង្គ្រោះជាតិ១១នាក់ត្រូវបានផ្តន្ទាទោសពាក់ព័ន្ធនឹងការតវ៉ានៅទីលានប្រជាធិបតេយ្យក្នុងរាជធានីភ្នំពេញកាលពីឆ្នាំ២០១៤***

កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ សកម្មជនប្រឆាំងចំនួន ១១នាក់របស់ គ.ស.ជ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលចន្លោះពី ៧ឆ្នាំ ដល់ ២០ឆ្នាំ ដោយចោទប្រកាន់ពីបទកុបកម្ម ដោយសារតែពួកគេចូលរួមក្នុងការតវ៉ានៅទីលានប្រជាធិបតេយ្យក្នុងរាជធានីភ្នំពេញកាលពីខែកក្កដា ឆ្នាំ២០១៤។ កាលពីដើម

ខែសីហា ពីរថ្ងៃបន្ទាប់ពីនាយករដ្ឋមន្ត្រីហ៊ុន សែន ស្នើឱ្យធ្វើការចាប់ខ្លួនមនុស្សបន្ថែមទៀត សកម្មជន គ.ស.ជ បីរូបទៀតត្រូវបានចោទប្រកាន់ផងដែរពីបទចូលរួមចលនាកុប្បកម្មពាក់ព័ន្ធនឹងការតវ៉ាដូចគ្នានេះដែរ។ សាលក្រមមួយត្រូវបានធ្វើឡើងដោយខ្វះភស្តុតាងទាំងស្រុង។ ពុំមានភស្តុងតាងដែលគួរឲ្យជឿជាក់ដើម្បីគាំទ្រអំណះអំណាងលើកឡើងក្នុងពេលសវនាការ ដែលថាជនជាប់ចោទមានផែនការធ្វើ "កុបកម្ម" ឬដែលថាអ្នកទាំង១១នាក់នោះបានប្រព្រឹត្តអំពើហិង្សានោះឡើយ ។

នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ បាតុករបានប្រមូលផ្តុំគ្នានៅទីលានប្រជាធិបតេយ្យក្នុងរាជធានីភ្នំពេញដើម្បីគាំទ្រការប្រមូលផ្តុំរបស់ គ.ស.ជ អំពាវនាវឲ្យបញ្ឈប់បម្រាមលើការជួបប្រជុំជាសាធារណៈនៅទីលានប្រជាធិបតេយ្យ។ ការតវ៉ាដោយសន្តិវិធីបានប្រែក្លាយជាអំពើហិង្សាដោយមានការប៉ះទង្គិចរវាងកងកម្លាំងសន្តិសុខខណ្ឌដូនពេញ និងអ្នកតវ៉ា។ នៅចន្លោះខែសីហា និងខែវិច្ឆិកា ឆ្នាំ២០១៤ ជនជាប់ចោទទាំង១១នាក់នោះត្រូវបានចាប់ខ្លួនពីបទផ្តើមគំនិត ឬចូលរួមប្រព្រឹត្តអំពើហិង្សា ហើយក្រោយមកត្រូវបានចោទប្រកាន់ បើទោះជាមានការរាយការណ៍ថា អ្នកដឹកនាំការតវ៉ាបានព្យាយាមទប់ស្កាត់មិនឲ្យមានអំពើហិង្សា ជាជាងការផ្តើមឲ្យមានអំពើហិង្សា។ ការជំនុំជម្រះនោះបានចាប់ផ្តើមនៅខែធ្នូ ឆ្នាំ២០១៤ និងបានបន្តផ្អែកលើមូលដ្ឋានដែលលំអៀងរហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ ដែលប្រធានអង្គជំនុំជម្រះចេញសេចក្តីសម្រេចបើកសវនាការជារៀងរាល់ថ្ងៃ ដោយមិនខ្វល់ពីសំណើរបស់មេធាវីការពារក្តី ដើម្បីពិចារណាលើបញ្ហាសុខភាពរបស់កូនក្តីខ្លួន។

នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ តុលាការបានស្នើឲ្យភាគីធ្វើសេចក្តីសន្និដ្ឋានបិទ បើទោះបីជាមានតែវត្តមានមេធាវីម្នាក់ក្នុងចំណោម៩នាក់ និងមានសំណើពីជនជាប់ចោទឲ្យពន្យាពេលនីតិវិធីក៏ដោយ។ បន្ទាប់មកចៅក្រមបានថយទៅពិភាក្សា ហើយ១៥នាទីក្រោយមកបានប្រកាសសាលក្រម ដែលផ្តន្ទាទោសជនជាប់ចោទយ៉ាងធ្ងន់ធ្ងរ។

ការជំនុំជម្រះទាំងមូលត្រូវបានរំខានដោយមានការជ្រៀតជ្រែកផ្នែកនយោបាយ។ សកម្មជននានាត្រូវបានចាប់ខ្លួនក្នុងអំឡុងពេលចរចាលើការបង្កើតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដោយមានការចាប់ខ្លួនក្រោមហេតុផលនយោបាយ។ នៅខែមេសា ឆ្នាំ២០១៥ សកម្មជនទាំង៥នាក់ដែលស្ថិតក្រោមការឃុំខ្លួនបណ្តោះអាសន្នត្រូវបានដោះលែងឲ្យនៅក្រៅឃុំបន្ទាប់ពីមានការបង្កើតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី ដែលនេះបញ្ជាក់ពីការជ្រៀតជ្រែកផ្នែកនយោបាយបន្ថែមទៀតក្នុងនីតិវិធីតុលាការ។ ការសម្រេចផ្តន្ទាទោសធ្វើឡើងខណៈដែលគណបក្សប្រឆាំងដកខ្លួនចេញពីការអនុម័តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងការដែល គ.ស.ជ បន្តពាក់ព័ន្ធនឹងភាពតានតឹងនៅតាមបណ្តោយព្រំដែនកម្ពុជា~វៀតណាម។

## អង្គការ និងសមាគម

អាជ្ញាធរអន្តរកាលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (អ៊ុនតាក់) ដែលបានគ្រប់គ្រងប្រទេសកម្ពុជាយ៉ាងមានប្រសិទ្ធភាពអស់រយៈពេល១៨ខែ នៅក្នុងឆ្នាំ១៩៩២ដល់ឆ្នាំ១៩៩៣ បានរាប់បញ្ចូលគោលដៅមួយក្នុងចំណោមគោលដៅសំខាន់ៗរបស់ខ្លួនគឺការបង្កើតឲ្យមានលំហសម្រាប់អង្គការសង្គមស៊ីវិល។ ទិសដៅសំខាន់ផ្សេងទៀត ក្នុងនោះរួមមានទាំងការកសាងសន្តិភាព ការធានានូវការគោរពដល់ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ និងការបញ្ឈប់ភ្លើងសង្គ្រាមដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា។ អ្នកសង្កេតការណ៍ជាច្រើនយល់ថា ជ័យជំនះដ៏យូរអង្វែងរបស់អ៊ុនតាក់ គឺការបង្កើតអង្គការមិនមែនរដ្ឋាភិបាល។ អង្គការមិនមែនរដ្ឋា

ភិបាលនៅកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានានូវការគោរពលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សក្នុងកម្រិតអប្បបរិមាចាប់តាំងពីដើមទស្សវត្សឆ្នាំ១៩៩០មក។ ទោះជាយ៉ាងណាក៏ដោយ ចលនានៃបង្កើតច្បាប់របស់រដ្ឋាភិបាលនាពេលថ្មីៗនេះ កំពុងគំរាមកំហែងដើម្បីបំផ្លាញឥទ្ធិពលដ៏វិជ្ជមានរបស់សង្គមស៊ីវិលនៅកម្ពុជា និងដាក់ទោសព្រហ្មទណ្ឌទៅលើបុគ្គលណាដែលហ៊ានជំទាស់នឹងសកម្មភាពរបស់រដ្ឋាភិបាល។

*ករណីសិក្សា៖ ការចាប់ខ្លួនសកម្មជនអង្គការមាតាធម្មជាតិនៅខេត្តកោះកុង*

ករណីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ យុវជនបីនាក់ដែលជាសមាជិករបស់អង្គការបរិស្ថានមាតាធម្មជាតិត្រូវបានចាប់ខ្លួន បន្ទាប់ពីបដិសេធបង្ហាញខ្លួនដើម្បីធ្វើការសាកសួរពាក់ព័ន្ធនឹងការចូលរួមរបស់ពួកគេក្នុងការតវ៉ាប្រឆាំងនឹងក្រុមហ៊ុនបូមខ្សាច់វៀតណាមនៅស្រុកបទុមសាគរ ខេត្តកោះកុង។ យុវជនទាំងបីនាក់ត្រូវបានចោទប្រកាន់ពីបទ *"គំរាមបំផ្លិចបំផ្លាញដោយមានបញ្ហា"* ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអប្បបរមារយៈពេលពីរឆ្នាំ។

សកម្មជនអង្គការមាតាធម្មជាតិបានចូលរួមក្នុងការតវ៉ាអហិង្សា ដោយសន្តិវិធីប្រឆាំងនឹងសកម្មភាពបូមខ្សាច់ដ៏ចម្រូងចម្រាស់នេះ។ ប្រតិបត្តិការបូមខ្សាច់បានបង្កឲ្យមានការបារម្ភធ្ងន់ធ្ងរពីសកម្មជនបរិស្ថាន ទេសចរណ៍ និងអ្នកភូមិនៅតំបន់នោះដែលបានលើកឡើងថា សកម្មភាពបែបនេះបំផ្លាញដល់ប្រព័ន្ធព្រៃកោងកាង និងបរិស្ថាននៅក្នុងតំបន់នោះ។ ពួកគេក៏បានចោទប្រកាន់ក្រុមហ៊ុនពីការបំពុលនៅតាមច្រាំងទន្លេ បង្កឲ្យបាក់ច្រាំង និងធ្វើឲ្យបាត់បង់ជម្រកត្រី។ មន្ត្រីនគរបាលខេត្តកោះកុង លោក សុំឃិត វៀន ត្រូវបានរាយការណ៍ថា ការចាប់ខ្លួននោះពាក់ព័ន្ធនឹងករណីបណ្តឹងពីរ ដែលក្នុងនោះ ករណីមួយប្តឹងដោយក្រុមហ៊ុនពីបទបំផ្លិចបំផ្លាញ ហើយមួយទៀតពីសំណាក់អាជ្ញាធរដែលអះអាងថាសកម្មជនទាំងនោះបានបង្កការរំខានដល់វេទិកាសាធារណៈមួយ។

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ សកម្មជនអង្គការមាតាធម្មជាតិបីនាក់ផ្សេងទៀតត្រូវបានចាប់ខ្លួនដោយសារធ្វើការតវ៉ាដោយពុំមានការអនុញ្ញាត ខណៈពេលព្យាយាមធ្វើការតវ៉ាដោយសន្តិវិធីមួយនៅខាងមុខរដ្ឋសភាក្នុងរាជធានីភ្នំពេញ និងត្រូវបាននាំខ្លួនទៅស្នងការនគរបាលខណ្ឌចំការមនដើម្បីសាកសួរ។ ពួកគេត្រូវបានដោះលែងវិញបន្ទាប់ពីមានការសាកសួរជាច្រើនម៉ោងដោយពុំមានការចោទប្រកាន់។ ជាថ្នូរនឹងការដោះលែងសកម្មជនទាំងនោះត្រូវបានស្នើឲ្យចុះហត្ថលេខាលើលិខិតមួយដោយសន្យាថា ពួកគេនឹងមិនចូលរួមដឹកនាំ ឬញុះញង់ឲ្យមានការតវ៉ាដោយគ្មានការអនុញ្ញាតនៅពេលអនាគត។

ក្រោយមក នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ មនុស្សចំនួន១៧នាក់ រួមមាន អ្នកឃ្លាំមើលសិទ្ធិមនុស្ស អ្នកសារព័ត៌មាន ពេទ្យ និងអ្នកតវ៉ា ត្រូវបានចាប់ខ្លួននៅខាងក្រៅតុលាការខេត្តកោះកុង ដែលអ្នកតវ៉ាបានប្រមូលផ្តុំគ្នាដើម្បីទាមទារឲ្យមានការដោះលែងសកម្មជនអង្គការមាតាធម្មជាតិទាំងបីនាក់នោះ។ មុននោះប៉ុន្មានសប្តាហ៍ អាជ្ញាធរខេត្តកោះកុងបានប្រកាសហាមឃាត់តាមអំពើចិត្តទៅលើការតវ៉ានៅមុខសាលាខេត្តកោះកុង។ សាក្សីបានបញ្ជាក់ថា នគរបាលបានចុះមកដល់ និងធ្វើការបំបែកដោយហិង្សាលើការតវ៉ានោះ ដែលបង្កឲ្យស្ត្រីម្នាក់សន្លប់ និងអ្នកផ្សេងទៀតរងរបួស។ ការចាប់ខ្លួនអ្នកឃ្លាំមើលសិទ្ធិមនុស្សដែលមានពាក់អាវសំគាល់ថាពួកគេមិនមែនជាអ្នកតវ៉ា គឺជាភស្តុតាងបង្ហាញឲ្យឃើញថា អាជ្ញាធរកម្ពុជាកាន់តែមិនគោរពតាមស្តង់ដាសិទ្ធិមនុស្ស។

*ករណីសិក្សា៖ ករណីទីមួយនៃការអនុវត្តន៍ច្បាប់សមាគម អង្គការមិនត្រឹមត្រូវ*

ចាប់តាំងពីមានការចែកចាយសេចក្តីព្រាងច្បាប់លើកទីមួយមក សង្គមស៊ីវិលមានការព្រួយបារម្ភអំពីការអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំពោះអង្គការសហគមន៍ថ្នាក់មូលដ្ឋាន និងក្រុមចលនាក្រៅផ្លូវការផ្សេងទៀត។ ប៉ុន្មានថ្ងៃបន្ទាប់ពីការអនុម័តច្បាប់ចុងក្រោយ ហើយបើទោះបីជាមានការធានាថាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនឹងមិនត្រូវបានប្រើដើម្បីរឹតត្បិតចលនាពលរដ្ឋនៅតាមសហគមន៍មូលដ្ឋាន ប៉ុន្តែការបារម្ភនោះបានក្លាយជាការពិតមែន។

កាលពីឆ្នាំមុន ក្រុមប្រជាពលរដ្ឋចំនួន ៦៩ គ្រួសាររស់នៅក្នុងឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះបានរួមគ្នាជាសហគមន៍សម្តែងនូវក្តីបារម្ភទាក់ទិននឹងទំនាស់លើដីធ្លីទំហំ២៥០ហិកតា។ នៅថ្ងៃសៅរ៍ ទី១៥ ខែសីហា ឆ្នាំ២០១៥ អធិការរងស្រុកស្នួលលោក ណុម ស្រ៊ុន បានកោះហៅតំណាងសហគមន៍ពីររូបក្នុងចំណោមគ្រួសារទាំងអស់មកកាន់ស្នងការនគរបាលស្រុក និងបានប្រាប់តំណាងសហគមន៍ឲ្យក្រុមនេះ ត្រូវតែចុះបញ្ជីនៅក្រសួងមហាផ្ទៃ ដែលអនុវត្តទៅតាមច្បាប់ថ្មីស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ យោងតាមអ្នកតំណាងមួយរូបបានឲ្យដឹងថា អធិការរងស្រុកបានស្នើឲ្យក្រុមនេះចុះកិច្ចសន្យាឈប់ចូលរួមក្នុងសកម្មភាពតវ៉ាទាំងឡាយរហូតទាល់តែក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជីក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងបានគំរាមដាក់ពិន័យប្រសិនបើក្រុមនេះមិនគោរពតាម។ នៅពេលទាក់ទងដើម្បីសាកសួរព័ត៌មានអំពីករណីនេះ អធិការរងស្រុកលោក ណុម ស្រ៊ុន បានអះអាងថា លោកពិតជាបានប្រាប់សហគមន៍ថាក្រោមច្បាប់សមាគមអង្គការ ក្រុមសហគមន៍តម្រូវឲ្យចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ។

ខែសីហា ឆ្នាំ២០១៥ ម.ស.ម.បានសរសេរលិខិតទៅកាន់ក្រសួងមហាផ្ទៃស្វែងរកការបញ្ជាក់ទៅលើបញ្ហានេះហើយទទួលបានការឆ្លើយតបនៅថ្ងៃទី២២ ខែកញ្ញា។[24] ដោយមានការលើកទឹកចិត្ត លិខិតឆ្លើយតបពីក្រសួងបានបញ្ជាក់ថាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមិនគួរអនុវត្តទៅលើសហគមន៍នៅថ្នាក់មូលដ្ឋានឡើយតែទោះជាយ៉ាងណាក្នុងលិខិតនោះបានបញ្ជាក់ថាសហគមន៍នៅឃុំឃ្សឹមត្រូវតែចុះបញ្ជីដោយសារពួកគេចង់ឲ្យមានការទទួលស្គាល់ជាសហគមន៍ជនជាតិដើមភាគតិច។ ម.ស.ម.ក ស្វាគមន៍ចំពោះទំនាក់ទំនងនេះពីក្រសួងជាពិសេសការបញ្ជាក់ពីការអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនេះត្រឹមត្រូវចំពោះសហគមន៍។ ទោះបីជាយ៉ាងណា ម.ស.ម.ក ជឿជាក់ថា សហគមន៍នៅឃុំឃ្សឹមត្រូវការឲ្យមានការបកស្រាយបន្ថែមទៀត។ ខណៈដែលអាជ្ញាធរមូលដ្ឋាននៅឃុំឃ្សឹមបានប្រាប់សហគមន៍ឲ្យចុះបញ្ជីតាមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ក្រសួងមហាផ្ទៃបានយោងទៅលើច្បាប់ភូមិបាល។ ម.ស.ម.ក ជឿជាក់ថាករណីពីរនេះគឺមិនពាក់ព័ន្ធគ្នានោះទេ។ កាដែលសហគមន៍ទាមទារកម្មសិទ្ធិដីសហគមន៍ នោះមិនគួរកំណត់ថាតើស្ថិតនៅក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនោះទេ ហើយការអនុវត្តសិទ្ធិសេរីភាពជួបប្រជុំដោយសន្តិវិធីក៏ពុំមានអ្វីប៉ះពាល់នឹងការទាមទារកម្មសិទ្ធិសហគមន៍ដែរ។

***ករណីសិក្សា ៖ សកម្មជនសហគមន៍បឹងកក់***

នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ត្រីសហគមន៍បឹងកក់ចំនួន ៧ នាក់ត្រូវបានចាប់ខ្លួននៅពេលធ្វើការតវ៉ាដើម្បីឲ្យអាជ្ញាធរដោះស្រាយបញ្ហាទឹកជន់លិចនៅសហគមន៍របស់ខ្លួន។ តំបន់នោះបានទទួលរងបញ្ហាទឹកជន់លិចចាប់តាំងពីឆ្នាំ២០០៨ នៅពេលដែលប្រជាពលរដ្ឋជិត២០០០០នាក់ត្រូវបានបណ្តេញចេញដោយបង្ខំ

---

[24] លិខិតចំហ ស្នើការបញ្ជាក់អំពីការអនុវត្តន៍ច្បាប់ស្តីពីសមាគមអង្គការនៅថ្នាក់មូលដ្ឋាន និងក្រុមបណ្តាញក្រៅផ្លូវការ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ អាចស្វែងរកបានតាមរយៈ http://bit.ly/1OU9Sp0។

និងបឹងនោះត្រូវបានចាក់ខ្សាច់លុបដោយក្រុមហ៊ុនស៊ូកាគូអ៊ីន ជាកម្មសិទ្ធិរបស់សមាជិកព្រឹទ្ធសភាគណបក្សប្រជាជនកម្ពុជា។

បន្ទាប់ពីការចាប់ខ្លួនអស់រយៈពេល៣៦ម៉ោង ពួកគេត្រូវបានចោទប្រកាន់ពីបទរារាំងចរាចរណ៍សាធារណៈ ហើយត្រូវបានកាត់ទោសនិងផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិចរយៈពេល១ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០០ដុល្លា។ នៅថ្ងៃសវនាការនោះ សកម្មជនចំនួនបីនាក់ផ្សេងទៀត និងព្រះសង្ឃមួយព្រះអង្គត្រូវបានចាប់ខ្លួនផងដែរ ដោយសារតែចូលរួមការតវ៉ាដោយសន្តិវិធីក្នុងការទាមទារឱ្យដោះលែងសកម្មជនទាំងនោះ។ ពួកគេត្រូវបានចោទប្រកាន់ពីបទរារាំងមន្ត្រីសាធារណៈដោយមានស្ថានទម្ងន់ទោស និងទទួលទោសដូចគ្នានឹងអ្នកទាំង៧នាក់នោះដែរ។

ខណៈដែលមានការបន្ថយទោស និងការពិន័យជាប្រាក់មួយចំនួន សាលាឧទ្ធរណ៍បានតម្កល់ការចោទប្រកាន់លើពួកគេនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីនីតិវិធីមួយធ្វើឡើងមិនស្របតាមបទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌។ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៥ បន្ទាប់ពីសកម្មជនទាំងនោះបានទទួលព្រះរាជទានលើកលែងទោសពីព្រះមហាក្សត្រ និងត្រូវបានដោះលែងឲ្យមានសេរីភាពបន្ទាប់ពីត្រូវបានឃុំខ្លួន ជាច្រើនខែក្នុងពន្ធនាគារ ដោយសារតែការអនុវត្តន៍សិទ្ធិសេរីភាពជាមូលដ្ឋានរបស់ខ្លួន។ ពួកគេមិនគួរត្រូវបានកាត់ទោសដោយសារការធ្វើបាតុកម្មដោយសន្តិវិធី និងការលើកឡើងនូវបញ្ហាកើតមាននៅសហគមន៍ខ្លួនតាំងពីដំបូងមកម្លេះ។

## អ្នកប្រើបណ្តាញអ៊ីនធឺណិត

ការប្រើប្រាស់អ៊ីនធឺណិតកំពុងតែកើនឡើងនៅប្រទេសកម្ពុជា និងមានការកើនឡើងនូវចំនួន "*អ្នកប្រើប្រាស់*"ជាច្រើន រួមមាន អ្នកសរសេរប្លុក អ្នកសារព័ត៌មាន អ្នកចែកចាយព័ត៌មាន អង្គការមិនមែនរដ្ឋាភិបាល ("អង្គការ") សកម្មជន និងនិស្សិតសាកលវិទ្យាល័យ ដោយពួកគេបានចាប់ផ្តើមប្រើប្រាស់បណ្តាញអ៊ីនធឺណិតក្នុងនោះរួមទាំងគេហទំព័របណ្តាញផ្សព្វផ្សាយសង្គម ដើម្បីចែករំលែកព័ត៌មាន និងគំនិតយោបល់នានា ដែលពេលខ្លះអាចចាត់ទុកថាជាការរិះគន់ទៅលើរដ្ឋាភិបាលកម្ពុជាផងដែរ។ ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិតកំពុងតែមានការកើនឡើងយ៉ាងលឿន ហើយតាមការសន្មតនាពេលថ្មីៗនេះ (ចាប់ពីពាក់កណ្តាលឆមាសទីពីរក្នុងឆ្នាំ ២០១៥) អ្នកប្រើប្រាស់អ៊ីនធឺណិតមានជាង៤១%នៃចំនួនប្រជាពលរដ្ឋសរុប ជាតួលេខមួយខ្ពស់ បើប្រៀបធៀបនឹងស្ថិតិរបស់ធានាគារពិភពលោកចាប់ពីឆ្នាំ២០១០ ដែលបានបង្ហាញថាអត្រាប្រើប្រាស់អ៊ីនធឺណិតកើនឡើងត្រឹមតែ១.៣ភាគរយប៉ុណ្ណោះ។ បណ្តាញអ៊ីនធឺណិតកំពុងតែក្លាយជាវេទិកាបឋមដ៏សំខាន់សម្រាប់ការជជែកដេញដោលផ្នែកនយោបាយនៅកម្ពុជា នៅពេលសកម្មនិយម និងការតស៊ូមតិរបស់ប្រជាពលរដ្ឋទូទៅកំពុងតែខិតទៅរកលទ្ធិប្រជាធិបតេយ្យ ពិតប្រាដក។ ក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោតឆ្នាំ២០១៣ ការធ្វើយុទ្ធនាការនៅលើបណ្តាញអ៊ីធឺណិត ត្រូវគេមើលឃើញថាជាវេទិកាស្នូលដែលនាំឱ្យគណបក្សកាន់អំណាច បាត់សំឡេងឆ្នោតគាំទ្រយ៉ាងច្រើនដែលមិនធ្លាប់មានពីមុនមក។ ចក្ខុវិស័យរបស់អង្គការសង្គមស៊ីវិលគឺថា ទំនាក់ទំនងនៅលើបណ្តាញអ៊ីធឺណិតបានក្លាយជាឧបករណ៍សំខាន់មួយក្នុងការឃ្លាំមើលសិទ្ធិមនុស្ស និងការបោះឆ្នោត ដែលអាចមានប្រតិកម្មភ្លាមៗទៅលើករណីរំលោភសិទ្ធិមនុស្ស។ កាលពីមុន អ៊ីនធឺណិតជាលំហសេរីនៅ

កម្ពុជា ប៉ុន្តែស្ថានភាពបច្ចុប្បន្ននេះកំពុងទទួលរងការវាយប្រហារលើសេរីភាពអ៊ីធឺណិត និងសិទ្ធិឌីជីថលពីសំណាក់រដ្ឋាភិបាល។

*ករណីសិក្សា ៖ និស្សិតម្នាក់ជាប់ពន្ធនាគារដោយសារបង្ហោះមតិយោបល់នៅលើបណ្ដាញសង្គមហ្វេសប៊ុក*

កាលពីថ្ងៃសុក្រ ទី២១ ខែសីហា ឆ្នាំ២០១៥ គង់ រ៉ាយ៉ា ជានិស្សិតនៃសាកលវិទ្យាល័យខេមរៈ ត្រូវបានសមត្ថកិច្ចចាប់ និង ឃុំខ្លួននៅពន្ធនាគារព្រៃសក្នុងរាជធានីភ្នំពេញ។ ថ្ងៃបន្ទាប់លោកត្រូវបានសាលាដំបូងរាជធានីភ្នំពេញចោទប្រកាន់ពីបទញុះញង់ ។ មួយខែមុនការចាប់ខ្លួន រ៉ាយ៉ាបានបង្ហោះសារនោះនៅលើគេហទំព័រហ្វេសប៊ុករបស់ខ្លួន ដោយអំពាវនាវឲ្យមាន *"បដិវត្តន៍ពណ៌... ដើម្បីផ្លាស់ប្ដូររបប"* ។[25] ដោយសារការសម្ដែងមតិនេះ គង់ រ៉ាយ៉ា បានប្រឈមនឹងការជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ។ ដោយគាំទ្រចំពោះការពារការចាប់ខ្លួននោះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃឯកឧត្តម ស ខេង បានថ្លែងថា បដិវត្តន៍ពណ៌នឹង *"ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខជាតិ និងសន្តិភាព ការរស់នៅ និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ"*។[26] បើទោះជា ពាក្យ *"បដិវត្តន៍ពណ៌"* នេះមានប្រភពមកពីការតវ៉ាដោយសន្តិវិធីដែលបានកើតឡើងនៅអតីតសហភាពសូវៀត ដែលបានអំពាវនាវឱ្យធ្វើកំណែទម្រង់លទ្ធិប្រជាធិបតេយ្យ និងសង្គមក៏ដោយ។ គង់ រ៉ាយ៉ា កំពុងស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្នដោយរង់ចាំសវនាជំនុំជម្រះ។

ករណីនេះ និងករណីចោទប្រកាន់លោក ហុង សុខហួរ បានពិពណ៌នាលម្អិតខាងលើនោះ បង្ហាញថារដ្ឋាភិបាលកំពុងកំណត់មុខសញ្ញាអ្នកប្រើប្រាស់អ៊ីនធឺណិត និងគាបសង្កត់ទៅលើសេរីភាពខាងការបញ្ចេញមតិនៅតាមបណ្ដាញបច្ចេកវិទ្យា ដោយមិនទាន់ផ្អែកតាមច្បាប់ស្ដីពីបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យានោះផង។

## សហជីពក្នុងវិស័យការងារ

នាពេលថ្មីៗនេះ សហជីពវិស័យការងារនៅកម្ពុជា បានទទួលភាពជោគជ័យទៅលើភាពងាយគ្រោះ និងប្រាក់ខែទាបរបស់កម្មករ ជាពិសេសក្នុងវិស័យកាត់ដេរដ៏សំខាន់របស់ប្រទេស។ ជាញឹកញាប់មានការផ្ទុះឡើងនូវអំពើហិង្សាធ្ងន់ធ្ងរនៅតាមរោងចក្រកាត់ដេរនាពេលកន្លងមក ដោយសារតែមានកូដកម្មតវ៉ា របស់កម្មកររោងចក្រកាត់ដេរ ប៉ះទង្គិចគ្នាជាមួយកងកម្លាំងសន្តិសុខ។ កូដកម្មតវ៉ារបស់កម្មករធ្វើឡើងបន្ទាប់ពីការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៣ ដោយមានការបង្ក្រាបយ៉ាងឃោរឃៅ ដោយអ្នកតវ៉ាចំនួន៥នាក់ត្រូវបានសម្លាប់ក្នុងឧប្បត្តិហេតុនោះកាលពីខែមករា ឆ្នាំ២០១៤។ ការណ៍នោះនាំឱ្យអង្គការមិនមែនរដ្ឋាភិបាល សហជីព ត្រូវបានរដ្ឋាភិបាលដាក់ការសង្ស័យ និងស្ថិតនៅក្រោមការតាមដាន ហើយបច្ចុប្បន្ននេះបានប្រឈមនឹងច្បាប់ដែលចរិតរឹតត្បិតទៅលើសិទ្ធិសេរីភាពខាងការបង្កើតសមាគម ការប្រមូលផ្ដុំ និងការបញ្ចេញមតិ។

---

[25] អួន ភាព "សាកលវិទ្យាធិការលើកឡើងថា ធ្លាប់បានដាស់តឿននិស្សិតម្នាក់កុំឲ្យធ្វើសកម្មភាពនយោបាយ" កាសែតឌឺ ខេមបូឌាដេលី ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ អាចស្វែងរកបានតាមរយៈគេហៈ http://www.cambodiadailykhmer.com/news/27214/

[26] ម៉ិច ដារ៉ា "រដ្ឋមន្ត្រីមហាផ្ទៃថ្លែងការពារការចាប់ខ្លួនករណីនៅលើហ្វេសប៊ុក" *ឌឺ ខេមបូឌាដេលី* ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥។ https://www.cambodiadaily.com/news/interior-minister-defends-facebook-post-arrests-94489/

ស្ថានភាពដ៏គ្រោះថ្នាក់នៃសេរីភាពបង្កើតសមាគមនៅកម្ពុជា មានសក្តានុពលរហូតឈានទៅដល់ការអនុម័តច្បាប់ស្តីពីសហជីព ដែលចំណុចនេះត្រូវបានពិភាក្សា រួចមកហើយនៅផ្នែកទីពីរខាងលើ។ សេចក្តីព្រាងច្បាប់ដ៏ចម្រូងចម្រាស់ដែលមានគោលបំណងកាត់បន្ថយឥទ្ធិពលរបស់អង្គការក្នុងវិស័យការងារ បច្ចុប្បន្ននេះកំពុងស្ថិតនៅក្នុងការពិនិត្យ ហើយនឹងត្រូវបញ្ជូនទៅកាន់សភាដើម្បីអនុម័តនាពេលឆាប់ៗ។

***ករណីសិក្សា ៖ ការបង្ក្រាបទៅសកម្មជនសហជីពការងារ ខែមករា ដល់ខែឧសភា ឆ្នាំ២០១៤***

នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៤ នគរបាល និងកងរក្សាសន្តិសុខ បានចាប់ខ្លួន លោកសុខ ឈុនអឿង អនុប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ("អាយឌា") ខណៈលោកព្យាយាមរៀបចំការតវ៉ាឱ្យមានការដោះលែងមនុស្សចំនួន២៣នាក់ ដែលត្រូវបានឃុំខ្លួនចាប់តាំងពីមានការប៉ះទង្គិចគ្នាដោយវាំងកងរក្សាសន្តិសុខ និងកម្មករ ដែលបានកើតឡើងកាលពីថ្ងៃទី២ និងថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤។ លោកត្រូវបានឃុំខ្លួនអស់រយៈពេល១យប់នៅស្នងការនគរបាលក្រុងភ្នំពេញ និងត្រូវបានដោះលែងវិញនៅម៉ោងប្រមាណ១០:០០នាទីព្រឹក នៅព្រឹកបន្ទាប់ ក្រោយពីលោកបានចុះហត្ថលេខាលើលិខិតជាលាយលក្ខណ៍អក្សរមួយច្បាប់យល់ព្រមឈប់ធ្វើសកម្មភាពខុសច្បាប់នានា ដោយមិនឱ្យមានការញុះញង់ឱ្យមានបាតុកម្មខុសច្បាប់ និងរាយការណ៍សកម្មភាពខុសច្បាប់នានា ហើយធ្វើការសហការជាមួយរដ្ឋាភិបាល។

នៅព្រឹកថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ កងកម្លាំងសន្តិសុខបានចាប់ខ្លួនសកម្មជនការពារសិទ្ធិមនុស្សចំនួន១១នាក់ដាក់ក្នុងមន្ទីរឃុំឃាំងនៅស្នងការនគរបាលក្រុងភ្នំពេញ។ សកម្មជនទាំង១១នាក់នោះបានព្យាយាមដាក់ញត្តិទៅកានស្ថានទូតបរទេសនានា រួមមាន ស្ថានទូតអាមេរិក និងស្ថានទូតបារាំង ដោយស្នើឱ្យមានការដោះលែងបាតុករទាំង ២៣ នាក់ដែលអាជ្ញាធរបានឃុំខ្លួនក្នុងការបង្ក្រាបមួយរបស់កម្មករកាត់ដេរកាលពីថ្ងៃទី២-៣ ខែមករា។ ក្នុងចំណោមអ្នកទាំងនោះ មាន៨នាក់ជាសកម្មជនសហគមន៍បឹងកក់ លោក រ៉ុង ឈុន ប្រធាន សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យជាង ជីតា បុគ្គលិករបស់សម្ព័ន្ធសហជីពកម្ពុជា និងកញ្ញា ឡុង គឹមហៀង មន្ត្រីទំនាក់ទំនង នៃលេខាធិការដ្ឋានក្រុមការងារពិសេសសិទ្ធិលំនៅឋាន។ ការចាប់ខ្លួននោះ ធ្វើឡើងនៅក្នុងអំឡុងពេលបាតុកម្មមួយនៅមុខស្ថានទូតសហរដ្ឋអាមេរិក នៅពេលពួកគេដាក់ញត្តិស្នើឱ្យធ្វើការដោះលែងអ្នកទាំង២៣នាក់នោះដែលបានជាប់ឃុំក្នុងអំឡុងពេលការបង្ក្រាបដោយហិង្សានៅទៅលើបាតុកម្មរបស់កម្មករកាត់ដេរនៅដើមខែមករា។ ក្រោយមកសកម្មជនទាំង១១នាក់ ត្រូវបានដោះលែងនៅថ្ងៃដដែលនោះ បន្ទាប់ពីត្រូវបានបង្ខំឱ្យចុះហត្ថលេខាសន្យាថានឹងមិនចូលរួម ឬដឹកនាំ ឬក៏ញុះញង់ឱ្យមានសកម្មភាព "*ខុសច្បាប់*" ឬការតវ៉ានៅពេលខាងមុខទៀត។

នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ ថ្នាក់ដឹកនាំចំនួន ៨ នាក់នៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ("ស៊ីខៅឌូ") ត្រូវបានចាប់ខ្លួននៅស្រុកបាទី ខេត្តតាកែវ ក្នុងអំឡុងពេលកូដកម្មរបស់កម្មករកាត់ដេរនៅរោងចក្រ JSD Textile Co.Ltd. កូដករបានស្នើឱ្យមានលក្ខខណ្ឌការងារល្អប្រសើរ។ ក្រោយមកសកម្មជនសហជីពចំនួន៨នាក់ត្រូវបានឃុំខ្លួនរយៈពេល៤៨ម៉ោង និងត្រូវបានសាកសួរពាក់ព័ន្ធករណីផ្តើមគំនិតឲ្យ

ប្រព្រឹត្តបទឧក្រិដ្ឋ គំរាមបង្កធ្វើឱ្យខូចខាត ធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចរបស់តុលាការ និងជាអ្នកញុះញង់។ អ្នកទាំងនោះត្រូវបានដោះលែងឱ្យស្ថិតនៅក្រៅឃុំនៅថ្ងៃទី២៥ ខែឧសភា បន្ទាប់ពីប្រធានសហជីពស៊ីខៅឌូ បានចុះហត្ថលេខាលើលិខិត ដោយសន្យាថាអ្នកទាំង៨នាក់នោះនឹងមិនបង្កឱ្យមានបញ្ហានៅរោងចក្រឡើយ ហើយនឹងបង្ហាញខ្លួននៅពេលព្រះរាជអាជ្ញាកោះហៅ។ ពួកគេត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ (ក្រោមមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ដោយសារការអនុវត្តន៍សិទ្ធិធ្វើកូដកម្មរបស់ខ្លួន ហើយពួកគេត្រូវបានចោទប្រកាន់ពីញុះញង់បង្កឱ្យមានអំពើហិង្សា និងការតវ៉ាខុសច្បាប់។

## ករណីអ្នកសារព័ត៌មាន

ជាតុផ្សំសំខាន់មួយទៀតនៃលទ្ធិប្រជាធិតេយ្យដែលល្អ គឺបណ្តាញផ្សព្វផ្សាយព័ត៌មានដែលរឹងមាំ និងឯករាជ្យ ដែលអាចឲ្យរដ្ឋាភិបាលមានទំនួលខុសត្រូវខ្ពស់។ នេះគឺជាជាតុផ្សំដ៏សំខាន់មួយនៃការទទួលបានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពទទួលបានព័ត៌មាន និងសិទ្ធិចូលរួមយ៉ាងពេញលេញក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច និងសង្គម។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ អ្នកសារព័ត៌មានជាតិ និងបុគ្គលិកបណ្តាញផ្សព្វផ្សាយព័ត៌មានមួយចំនួនត្រូវបានវាយប្រហារ ឃុំខ្លួន ព្រមទាំងសម្លាប់ ហើយការបោះពុម្ពផ្សាយត្រូវបានត្រួតពិនិត្យ ឬបិទ។

សារព័ត៌មានជាខេមរៈភាសា និងស្ថានីយទូរទស្សន៍នៅកម្ពុជា ភាគច្រើនត្រូវបានគ្រប់គ្រងដោយម្ចាស់គ្រឹស្ថានដែលមាននិន្នាការស្មោះស្ម័គ្រទៅលើគណបក្សកាន់អំណាច។ នៅពេលអ្នកសារព័ត៌មាន លើកឡើងពីទង្វើខុសឆ្គងរបស់រដ្ឋាភិបាល និងវិស័យឯកជន ជាញឹកញាប់ត្រូវទទួលរងការគំរាមកំហែងដល់អាយុជីវិត។ ជាក់ស្តែងមានអ្នកសារព័ត៌មានចំនួន ១៣ នាក់ហើយដែលត្រូវបានសម្លាប់រាប់ចាប់តាំងពីឆ្នាំ១៩៩៤ រហូតដល់ខែតុលា ឆ្នាំ២០១៤ ដោយសារសកម្មភាពការងាររបស់ខ្លួន។ ផែនទីបង្ហាញពីជីវប្រវត្តិរបស់អ្នកសារព័ត៌មានដែលបានបាត់បង់ជីវិតគឺមាននៅលើគេហទំព័រសិទ្ធមនុស្សរបស់ម.ស.ម.ក Sithi.org។[27]

***ករណីសិក្សា ៖ អ្នកសារព័ត៌មានវីអូឌី ត្រូវកងសន្តិសុខឃាយី ពេលរាយការណ៍អំពីការតវ៉ារបស់សហគមន៍បឹងកក់***

នៅក្នុងស្ថានភាពចុងក្រោយនៃអំពើហិង្សាទៅលើអ្នកសារព័ត៌មាន អ្នកយកព័ត៌មានពីរូបរបស់វិទ្យុសម្លេងប្រជាធិបតេយ្យ ("វី.អូ.ឌី") ជាផ្នែកមួយនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ត្រូវបានវាយប្រហារដោយកងកម្លាំងសន្តិសុខខ័ណ្ឌដូនពេញកាលដើមខែសីហា។ ពួកគេបានចុះទៅយកព័ត៌មានពីការធ្វើបាតុកម្មរបស់ប្រជាសហគមន៍បឹងកក់នៅមុខសាលាក្រុងភ្នំពេញ។ ពួកគេត្រូវបានឃាយី និងគំរាមដកហូតយកសម្ភារៈខណៈពេលព្យាយាមសម្ភាសន៍បាតុករមួយចំនួន។[28]

---

[27] គេហទំព័រ "សិទ្ធិ" ផែនទីនៃជីវប្រវត្តិអ្នកសារព័ត៌មានដែលត្រូវបានសម្លាប់ អាចស្វែរកបានតាមតំណ http://sithi.org/temp.php?url=jour_killed/journalists.html&lg។

[28] "ក្លឹបអ្នកកាសែតកម្ពុជាថ្កោលទោសចំពោះការវាយដំទៅលើអ្នកសារព័ត៌មាន" ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៥ អាចស្វែងរកបានតាមរយៈតំណ http://www.phnompenhpost.com/national/press-clubs-denounce-attack-journalists។

អាកប្បកិរិយាបែបនេះមិនមែនរឿងថ្មី សម្រាប់កងរក្សាសន្តិសុខខណ្ឌដូនពេញឡើយ ។ នៅខែឧសភា ឆ្នាំ២០១៤ លោក ឡាយ សាមាន អ្នកយកព័ត៌មានម្នាក់ទៀតរបស់ វី.អូ.ឌី ត្រូវបានវាយ ឲ្យសន្លប់នៅលើផ្លូវ នៅពេលលោកព្យាយាមថតយករូបភាពរបស់កងរក្សាសន្តិសុខទាំងនោះកំពុងដេញព្រះសង្ឃនៅពេលប្រមូលផ្តុំមួយរៀបចំឡើងដោយអ្នកគាំទ្រគណបក្សប្រឆាំងនៅទីលានប្រជាធិបតេយ្យក្នុងរាជធានីភ្នំពេញ។ លោកបានរងរបួសក្បាល និងបាក់ឆ្អឹងថ្ពាល់ ដែលត្រូវបានបញ្ជូនទៅកាន់ទីក្រុងបាងកកជាបន្ទាន់ដើម្បីព្យាបាល ដែលត្រូវចំណាយថ្លៃព្យាបាលអស់ទឹកប្រាក់ចំនួន៣០.០០០ដុល្លាអាមេរិក។ ភ្នែករបស់លោកពិកាជាអចិន្ត្រៃយ៍។ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ បានដាក់ពាក្យបណ្តឹងប្រឆាំងនឹងមន្ត្រីទទួលបន្ទុកកងរក្សាសន្តិសុខទាំងនោះ ដោយទាមទារប្រាក់សំណងសម្រាប់ថ្លៃព្យាបាល ប៉ុន្តែសាលាដំបូងរាជធានីភ្នំពេញច្រានចោលបណ្តឹងនេះ ដោយពុំមានការពន្យល់អ្វីឡើយ។ នគរបាល ឬតុលាមិនបានធ្វើការស៊ើបអង្កេតលើករណីព្រហ្មទណ្ឌនេះឡើយ បើទោះជាមានការថ្កោលទោសជុំវិញរឿងនេះក្តី។

## IV **សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

លទ្ធិប្រជាធិបតេយ្យនៅកម្ពុជាកំពុងស្ថិតនៅលើផ្លូវបំបែក។ ខណៈដែលការបោះឆ្នោតឆ្នាំ២០១៧ និងឆ្នាំ២០១៨ កាន់តែខិតជិតមកដល់ រដ្ឋាភិបាលកំពុងតែធ្វើយុទ្ធនាការកាន់តែខ្លាំងឡើងដើម្បីបិទសម្លេងជំទាស់ ។ ច្បាប់ដែលមានចរិតគាបសង្កត់ ការចាប់ខ្លួន និងការចោទប្រកាន់ដោយហេតុផលនយោបាយ ការយាយីទៅដល់សង្គមស៊ីវិល និងការបំបិទសម្លេងជំទាស់ ទាំងនេះជាការវាយប្រហារទៅលើលទ្ធិប្រជាធិបតេយ្យ។ នៅក្នុងបរិបទដែលមានការព្រួយបារម្ភខ្លាំងនេះ រដ្ឋាភិបាលបានបន្ទច់បង្អាក់លទ្ធិប្រជាធិបតេយ្យតាមរយៈរឹតត្បិតលើសេរីភាពជាមូលដ្ឋាន និងគាបសង្កត់សមត្ថភាពរបស់សង្គមស៊ីវិល និងប្រជាពលរដ្ឋកម្ពុជាពីការសម្តែងឆន្ទៈ និងចូលរួមកិច្ចការសាធារណៈដោយសេរី។

ក្រៅពីការបង្កើតច្បាប់ដើម្បីបង្ក្រាបរបស់រដ្ឋាភិបាលទៅលើសេរីភាពមូលដ្ឋាន និងយាយីតាមផ្លូវតុលាការទៅលើសំឡេងជំទាស់ អ្នកដែលមានលុយនឹងអាវុធជាច្រើននៅកម្ពុជាវិនិយោគច្រើនជាមួយនឹងគណបក្សកាន់អំណាច ប្រសិនបើគណបក្សប្រឆាំងទទួលបានជ័យជម្នះក្នុងការបោះឆ្នោតខាងមុខ ការផ្ទេរអំណាចដោយសន្តិភាព និងការគោរពទៅលើដំណើរការលទ្ធិប្រជាធិបតេយ្យនឹងមិនអាចធ្វើទៅបាន។

បើទោះជាមានការសន្យាម្តងហើយម្តងទៀតពីសំណាក់រដ្ឋាភិបាលដើម្បីចូលរួមក្នុងកំណែទម្រង់សំខាន់ៗ រួមមាន ការបង្កើនកិច្ចសហប្រតិបត្តិការជាមួយសង្គមស៊ីវិល វិធានការនានា និងសេចក្តីថ្លែងការណ៍ថ្មីៗតែងមានលក្ខណៈផ្ទុយគ្នា។ ភាពសម្ងាត់ និងកង្វះតម្លាភាពបន្តកើតមានឡើងនៅក្នុងដំណើរការតាក់តែងច្បាប់នៅកម្ពុជា ដោយរារាំងសង្គមស៊ីវិល និងបុគ្គលទាំងឡាយដែលអាចរងផលប៉ះពាល់ដោយច្បាប់នេះពីការបញ្ចេញមតិយោបល់ ឬចូលរួមចំណែកក្នុងការបង្កើតច្បាប់នេះ។ ស្ថានភាពរឹតត្បិតលើសេរីភាពមូលដ្ឋានបានកើនឡើងប៉ុន្មានខែចុងក្រោយនេះ។ គូបដិបក្ខនយោបាយ សង្គមស៊ីវិល សហជីព និងប្រជាពលរដ្ឋសាមញ្ញដែលប្រើប្រាស់បណ្តាញសង្គមត្រូវបានបំបិទសម្លេងរបស់ខ្លួន ខណៈដែលរដ្ឋាភិបាលបន្តគ្រប់គ្រងប្រព័ន្ធតុលាការ នឹងបង្កើតច្បាប់ដែលរំលោភទៅលើសេរីភាពមូលដ្ឋាន។

យោងតាមស្ថានភាពបានពិព័ណ៌នាខាងលើនេះ ម.ស.ម.ក នៅតែមានការព្រួយបារម្ភអំពីស្ថានភាពលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា និង សូមផ្តល់ជូនអនុសាសន៍មួយចំនួនដល់រដ្ឋាភិបាល ដូចខាងក្រោម ៖

- ធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដើម្បីធានាសេរីភាពខាងការបញ្ចេញមតិដល់អង្គការសង្គមស៊ីវិលក្នុងអំឡុងពេលបោះឆ្នោត។ ចំណុចគួរធ្វើវិសោធនកម្មរួមមាន ៖
  - លុបចោលបទប្បញ្ញត្តិដែលមានខ្លឹមសារមិនច្បាស់លាស់ គឺ មាត្រា ៨៤ មាត្រា១៣៧ មាត្រា១៤៨ និងមាត្រា ១៥៩ នៃ ច្បាប់ស្តីពីការជ្រើសតាំងតំណាងរាស្ត្រស្តីពីការចូលរួមរបស់អង្គការក្នុងសកម្មភាពពាក់ព័ន្ធនឹងការបោះឆ្នោត។
  - លុបចេញមាត្រា ១៦២ នៃច្បាប់ស្តីពីការជ្រើសតាំងតំណាងរាស្ត្រស្តីពីការលុបឈ្មោះរបស់គណបក្សនយោបាយ។
  - លុបចេញមាត្រា ៨៣ នៃច្បាប់ស្តីពីការជ្រើសតាំងតំណាងរាស្ត្រដែលអនុញ្ញាតឲ្យមន្ត្រីយោធា និងតុលាការចូលរួមក្នុងយុទ្ធនាការបោះឆ្នោត និង
  - ពិនិត្យឡើងវិញលើបទប្បញ្ញត្តិមួយចំនួនក្នុងមាត្រា១៦០ស្តីអំពីការដាក់ទោសទៅលើអ្នកសង្កេតការណ៍បោះឆ្នោតក្នុងអំឡុងពេលបោះឆ្នោត និងពេលរាប់សន្លឹកឆ្នោត។
- បញ្ឈប់ការអនុម័តច្បាប់ស្តីពីឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យា រហូតដល់មានការពិគ្រោះយោបល់ប្រកបដោយតម្លាភាពជាមួយសង្គមស៊ីវិលជាមុនសិន និងធានាថាបទប្បញ្ញត្តិណាមួយចែងពីអ្នកប្រើប្រាស់បណ្តាញអ៊ីនធឺណិតត្រូវតែដាក់ចេញឲ្យស្របនឹងរដ្ឋធម្មនុញ្ញ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។
- អោយមានការចូលរួមជាអត្ថិភាពក្នុងដំណើរការតាក់តែងច្បាប់ប្រកបដោយតម្លាភាព សម្រាប់ការអនុម័តច្បាប់ស្តីពីការទទួលបានព័ត៌មានឲ្យបានច្បាស់លាស់ ដែលច្បាប់នេះលើកកម្ពស់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងការទទួលបានព័ត៌មាន។
- និរាករណ៍ច្បាប់ស្តីពីសមាគមនិងអង្គការដែលទើបតែត្រូវបានអនុម័តនាពេលថ្មីៗនេះ។
- បញ្ឈប់ដំណើរការអនុម័តច្បាប់ស្តីពីសហជីព ប្រសិនបើច្បាប់នេះមិនមានការកែប្រែចំណុចសំខាន់ៗ និងមានកិច្ចពិគ្រោះយោបល់ដោយពិតប្រាកដដោយផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការវិភាគ និងមតិយោបល់។
- ធានាការគោរពសិទ្ធិសេរីភាពខាងការប្រមូលផ្តុំ និងបញ្ឈប់ការហាមប្រាមតាមអំពើចិត្ត ឬលុបចោលការហាមប្រាមមិនឱ្យធ្វើការប្រមូលផ្តុំជាសាធារណៈ។
- បញ្ឈប់ការយាយីផ្នែកតុលាការទៅលើអ្នកការពារសិទ្ធិមនុស្ស សកម្មជននយោបាយ និងអ្នកនយោបាយគណបក្សប្រឆាំង និងដោះលែងជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌចំពោះអ្នកដែលជាប់ឃុំនាពេលថ្មីៗនេះដោយសារការចោទប្រកាន់ ឬការចាប់ខ្លួន ក្រោមហេតុផលនយោបាយ ដែលគ្មានមូលដ្ឋានច្បាប់ និងមិនគួរកើតមានក្នុងសង្គមប្រជាធិបតេយ្យបែបពហុបក្ស។

- ជានាថា ករណីឃាឃីប្រឆាំងទៅលើអ្នកសារព័ត៌មាន បុគ្គលិកអង្គការ សមាជិកសហជីព និងតួអង្គសង្គមស៊ីវិលផ្សេងទៀតត្រូវបានស៊ើបអង្កេតដោយត្រឹមត្រូវ ហើយត្រូវនាំយកជនដៃដល់មកផ្តន្ទាទោសចំពោះទង្វើរបស់ពួកគេនៅចំពោះមុខច្បាប់។
- ជានាឲ្យមានការអនុវត្តន៍ទៅលើអនុសាសន៍ទាំងអស់ដែលបានលើកឡើងនៅក្នុងការត្រួតពិនិត្យជាសកលតាមកាលកំណត់ទៅលើប្រទេសកម្ពុជារបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅឆ្នាំ២០១៤ ។
- ជានាថា មន្ត្រីកងយោធពលខេមរៈភូមិន្ទប្រកាន់គោលជំហរអព្យាក្រឹត្យចំពោះគណបក្សនយោបាយ និងមិនឲ្យមន្ត្រីយោធាមានតំណែងជាផ្លូវការនៅក្នុងគណបក្សនយោបាយណាមួយ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង នាយិកាប្រតិបត្តិ ម.ស.ម.ក អ្នកស្រី ចក់ សុភាព តាមរយៈទូរស័ព្ទ៖ + ៨៥៥ (០) ១១ ៩៤៣ ២១៣ ឬ អ៊ីម៉ែល ៖ chaksopheap@cchrcambodia.org ឬ លោក ផាត ដឺប្រូនទីប្រឹក្សា ម.ស.ម.ក តាមរយៈទូរស័ព្ទ ៖ + ៨៥៥ (០) ៨៩ ៥៣ ៦២ ១៥ ឬ អ៊ីម៉ែល៖ pat.debrun@cchrcambodia.org។**

CC BY NC SA